ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍សង្ខេប
# ស្តីពីសមិទ្ធផលសំខាន់ៗមួយ
# ចំនួនរបស់រាជរដ្ឋាភិបាល
# នៃព្រះរាជាណាចក្រកម្ពុជា
# ២០០៨-២០១២

ទីស្តីការគណៈរដ្ឋមន្ត្រី
ខែឧសភា ឆ្នាំ២០១៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍សង្ខេប
# ស្តីពីសមិទ្ធផលសំខាន់ៗមួយ
# ចំនួនរបស់រាជរដ្ឋាភិបាល
# នៃព្រះរាជាណាចក្រកម្ពុជា
# ២០០៨-២០១២

ទីស្តីការគណៈរដ្ឋមន្ត្រី
ខែឧសភា ឆ្នាំ២០១៣

# មាតិកា

**ព័ត៌មានសង្ខេបសំខាន់ៗស្តីពីព្រះរាជាណាចក្រកម្ពុជា (ពីឆ្នាំ២០០៨-២០១២)** ០១
**អភិបាលកិច្ចល្អ** ០១
**១-ការប្រយុទ្ធប្រឆាំងអំពើពុករលួយ** ០១
**២-កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌** ០២
♦ចៅក្រម ០៣
♦ក្រឡាបញ្ជី ០៣
♦មេធាវី ០៣
♦អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក.) ០៣
**៣-កំណែទម្រង់រដ្ឋបាលសាធារណៈ** ០៣
ក-ការគ្រប់គ្រងក្របខ័ណ្ឌ ០៣
ខ-ការរៀបចំបៀវត្សមន្ត្រីរាជការ ០៤
គ-ការងារវិមជ្ឈការនិងវិសហមជ្ឈការ ០៤
**☆ការអភិវឌ្ឍថ្នាក់ក្រោមជាតិ** ០៤
ឃ-ការងារប្រជាធិបតេយ្យនីយកម្ម ០៥
♦ចំនួនគណបក្ស ០៥
♦លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ លើកទី១ ០៥
♦លទ្ធផលនៃការបោះឆ្នោតឡើងវិញ ដើម្បីជ្រើសរើសសមាជិកក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ០៦
♦លទ្ធផលនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣ ០៦
♦លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នីតិកាលទី៣ (២០១២-២០១៧) ០៦
ង-សង្គមស៊ីវិល ០៧
**☆សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម** ០៨

♦ការងារចុះបញ្ជីគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋ ០៨
♦គ្រោះថ្នាក់ចរាចរ ០៨
**☆សមាហរណកម្មកម្ពុជានៅក្នុងតំបន់និងពិភពលោក** ០៨
♦ព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃសមាគមប្រជាជាតិ
អាស៊ីអាគ្នេយ៍ (ASEAN) ០៨
♦ព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោក ០៨
♦ទំនាក់ទំនងការទូតរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយប្រទេសជាមិត្ត ០៩
♦ការបញ្ជូនកងយោធពលខេមរភូមិន្ទទៅចូលរួមជាមួយកងកម្លាំងរក្សាសន្តិភាពរបស់
អង្គការសហប្រជាជាតិ នៅក្រៅប្រទេស ០៩
**☆ការងារព្រំដែន** ០៩
ក.ជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម ០៩
ខ.ជាមួយសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ១០
គ.ជាមួយព្រះរាជាណាចក្រថៃឡង់ដ៍ ១០
**☆ច្រកទ្វារអន្តរជាតិ** (**ស្ថិតនៅផ្ទៃក្នុងព្រះរាជាណាចក្រកម្ពុជា**) ១០
**☆ច្រកទ្វារព្រំដែនអន្តរជាតិ** (**ស្ថិតនៅតាមព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជា
និងប្រទេសជិតខាង**) ១០
**បរិស្ថានម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ** ១១
**☆ផលិតផលសរុបក្នុងស្រុក** (GDP) ១១
**☆ការគ្រប់គ្រងពាណិជ្ជកម្ម** ១២
**☆ប្រព័ន្ធធនាគារនៅកម្ពុជា** (**ឆ្នាំ២០០៨-២០១២**) ១៣
**I-ការលើកស្ទួយវិស័យកសិកម្ម** ១៤
**១-ផលិតកម្មដំណាំស្រូវ** ១៤
**☆ដំណាំកៅស៊ូ និងការចិញ្ចឹមសត្វ** ១៥
**២-កំណែទម្រង់ជលផល** ១៥
**៣-កំណែទម្រង់ព្រៃឈើ** ១៦
**☆ការគ្រប់គ្រងបរិស្ថាន** ១៦
**☆ការងារគ្រប់គ្រងគ្រោះមហន្តរាយ** ១៧

**៤-កំណែទម្រង់ដីធ្លី និងការបោសសម្អាតមីន** ១៧
៤.១-កំណែទម្រង់ដីធ្លី ១៧
ក-ការងារចុះបញ្ជីដីធ្លី ១៧
ខ-ការបែងចែកដីក្នុងគោលដៅសម្បទានដីសង្គមកិច្ច និងប្រទានកម្ម ១៨
គ-ការគ្រប់គ្រងនិងការអភិវឌ្ឍវិស័យសំណង់ ១៨
៤.២-ការបោសសម្អាតមីន ១៩
**II-ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត** ១៩
**១-ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍** ១៩
**☆ស្ពាននិងផ្លូវដែកដែលបាន និងកំពុងស្ថាបនា គិតមកដល់ ដំណាច់ឆ្នាំ ២០១២** ២០
**☆ការដឹកជញ្ជូននៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ** ២០
**☆ការដឹកជញ្ជូននៅកំពង់ផែស្វយ័តភ្នំពេញ** ២១
**☆ការដឹកជញ្ជូនតាមផ្លូវអាកាស** ២១
☞ក្រុមហ៊ុនអាកាសចរណ៍ជាតិ និងអន្តរជាតិ ដែលមានច្បាប់អនុញ្ញាតហោះហើរ
ចេញ ចូលព្រះរាជាណាចក្រកម្ពុជា ២២
**២-ការអភិវឌ្ឍវិស័យថាមពល** ២៣
**☆ការដារសាងសង់វារីអគ្គិសនី** ២៤
**☆ការសាងសង់រោងចក្រផលិតថាមពលអគ្គិសនីដុតធ្យូងថ្ម** ២៤
**៣-ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ** ២៥
**៤-ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានគមនាគមន៍** ២៥
ក-ស្ថានីយទូរទស្សន៍ ២៦
ខ-ស្ថានីយវិទ្យុ ២៦
គ-សារព័ត៌មានបោះពុម្ព ២៦
**III-ការអភិវឌ្ឍវិស័យឯកជន និងការងារ** ២៦
**១-ការពង្រឹងវិស័យឯកជន និងការទាក់ទាញវិនិយោគ** ២៦
**២-ឧស្សាហកម្ម និងសិប្បកម្ម** ២៧
**៣-ការបង្កើតការងារ និងការធានាលក្ខខណ្ឌការងារល្អប្រសើរ** ២៨
**☆ការបង្កើតការងារ និងចំណូលពីវិស័យទេសចរណ៍** ២៨

✡ចំនួនភ្ញៀវទេសចរអន្តរជាតិ និងចំណូលពីការទិញសំបុត្រ
ចូលទស្សនារមណីយដ្ឋានអង្គរ ២៩
♦ រមណីយដ្ឋានទេសចរណ៍កំពុងពេញនិយម ២៩
៤-ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម ៣០
IV-ការកសាងសមត្ថភាពនិងធនធានមនុស្ស ៣០
១-ការពង្រឹងគុណភាពវិស័យអប់រំ ៣០
✡ ការបណ្តុះបណ្តាលនៅសាលាភូមិន្ទរដ្ឋបាល ៣២
២-ការលើកកម្ពស់វិស័យសុខាភិបាល ៣២
ក-មូលដ្ឋានសុខាភិបាលសាធារណៈ ៣២
ខ-ចំនួនមន្ត្រីសុខាភិបាល ៣៣
គ-ឱសថស្ថាន ឱសថស្ថានរង និងផ្ទះលក់ឱសថ ៣៣
ឃ-សេវាសុខាភិបាលឯកជន ៣៤
៣-កិច្ចការសាសនា ៣៤
ក-ព្រះពុទ្ធសាសនា ៣៤
ខ-អិស្លាមសាសនា ៣៤
គ-គ្រិស្តសាសនា ៣៥
៤-ការលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់សិទ្ធអំណាចដល់ស្ត្រី ៣៥
✡✡✡សមិទ្ធផលសំខាន់ៗ ដែលត្រូវបានសម្ពោធដាក់ឲ្យប្រើប្រាស់
ចាប់ពីឆ្នាំ២០០៩ដល់ឆ្នាំ២០១២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់
បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ៣៥
ក-ស្ពាន ៣៥
ខ-ផ្លូវជាតិ និងផ្លូវលំជនបទ ៣៦
គ-ស្ថានីយវារីអគ្គិសនី ៣៨
ឃ-ប្រព័ន្ធធារាសាស្ត្រ និងរោងចក្រផលិតទឹកស្អាត ៣៨
ង-អគារសិក្សា ៣៨
ច-រោងចក្រ ៣៨
ឆ-តំបន់សេដ្ឋកិច្ចពិសេស ៣៨
ជ-ចំណតផែកុងតែន័រភ្នំពេញថ្មី ៣៩
ឈ-សមិទ្ធផលក្នុងវិស័យព្រះពុទ្ធសាសនា ៣៩

# ព័ត៌មានសង្ខេបសំខាន់ៗស្តីពីព្រះរាជាណាចក្រកម្ពុជា
# (ពីឆ្នាំ២០០៨-២០១២)

| | |
|---|---|
| ផ្ទៃដីសរុបៈ គ.ម$^{២}$ | ១៨១ ០៣៥ |
| ចំនួនរាជធានី | ១ |
| ចំនួនខេត្ត | ២៣ |
| ចំនួនស្រុក | ១៥៩ |
| ចំនួនខណ្ឌ | ៩ |
| ចំនួនក្រុង | ២៦ |
| ចំនួនឃុំ | ១ ៤០៧ |
| ចំនួនសង្កាត់ | ២២៦ |
| ចំនួនភូមិ | ១៣ ៩២៣ |
| ប្រជាជនសរុបៈ ការធ្វើចំណោលឆ្នាំ២០១១(លាននាក់) | ១៤,៥ |
| ដង់ស៊ីតេប្រជាជន(ក្នុង១គ.ម$^{២}$) | ៨៤(២០០៨) |
| ប្រជាជនអាយុ ០-១៤ (% នៃប្រជាជនសរុប) | ៣៣,៦ |
| ប្រជាជនអាយុ ១៥-៦៤ (% នៃប្រជាជនសរុប) | ៦២,៤៧ |
| ប្រជាជនអាយុ ៦៥ឆ្នាំឡើងទៅ (% នៃប្រជាជនសរុប) | ៣,៨៨ |
| អត្រាកំណើនប្រចាំឆ្នាំ | ១,៣៤ |
| អត្រាបង្កើតកូនសរុប (ក្នុងស្ត្រីម្នាក់) (កំណើតរស់) | ២,៩១ |
| ចំនួនគ្រួសារ | ៣ ០៨០ ៦៩២ |

◆បន្ទាប់ពីការអនុវត្តនយោបាយ ឈ្នះឈ្នះ របស់រាជរដ្ឋាភិបាល ដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចាប់តាំងពីឆ្នាំ ១៩៩៨មក ព្រះរាជាណាចក្រកម្ពុជាបានទទួលសុខសន្តិភាព ឯកភាពជាតិ និងឯកភាពទឹកដីដ៏ពេញលេញរហូតមកដល់បច្ចុប្បន្ននេះ ហើយបានបង្កលក្ខណៈឲ្យមានការអភិវឌ្ឍលើគ្រប់វិស័យ។

## អភិបាលកិច្ចល្អ

### ១- ការប្រយុទ្ធប្រឆាំងអំពើពុករលួយ

អនុវត្តតាមច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដែលបានចូលជាធរមានកាលពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១ អង្គភាពប្រឆាំងអំពើពុករលួយបានសម្រេចនូវសមិទ្ធផលដែលគួររំលេចរួមមាន៖

◆បានអនុវត្តនូវច្បាប់ថ្មីមួយ ស្តីពីការប្រឆាំងអំពើពុករលួយ និងការអប់រំផ្សព្វផ្សាយនូវច្បាប់នេះដោយផ្ទាល់មាត់ និងតាមរយៈការបោះពុម្ព សោតទស្សន៍ ដែលប្រការនេះបានរួមចំណែកធ្វើឲ្យមានការប្រែប្រួលគួរឲ្យកត់សំគាល់នូវអាកប្បកិរិយាសង្គមទាំងមូល។

•បានអនុវត្តការប្រកាសទ្រព្យសម្បត្តិ និងបំណុល ដែលកំពុងធ្វើឲ្យមានទម្លាប់ថ្មីដល់មន្ត្រី និងជួយបានយ៉ាងមានប្រសិទ្ធភាពដល់ការទប់ស្កាត់ ក៏ដូចជាការស៊ើបអង្កេតនូវអំពើពុករលួយ។ មន្ត្រីជាប់កាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិនិងបំណុល ស្ទើរតែ១០០% បានបំពេញមុខនាទីនេះរបស់ខ្លួនប្រកបដោយស្មារតីវិន័យខ្ពស់។

•បានរកឃើញនូវកម្លាំងសរុបមួយ ក្នុងការប្រយុទ្ធប្រឆាំងការយកកម្រៃសេវាក្រៅច្បាប់ ហើយរួមគ្នាកសាងនូវការផ្ដល់សេវាសាធារណៈដែលនៅកៀកនឹងប្រជាជននិងទទួលបាននូវការជឿទុកចិត្ត ដូចផែនការដែលបានគូសវាសចេញដោយក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ។

•ការបង្រ្កាបនិងបញ្ជូនទៅតុលាការ នូវការដោះស្រាយពាក្យបណ្ដឹងកាន់តែមានប្រសិទ្ធភាព ក៏ជាការរួមចំណែកសំខាន់ចុងក្រោយ សម្រាប់ការកសាងសង្គមមួយស្អាតស្អំសមស្របនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

## ២-កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌

ក្នុងរយៈពេលពីឆ្នាំ២០០៩ មកដល់ ឆ្នាំ២០១២ រាជរដ្ឋាភិបាលបានបញ្ជូនសេចក្ដីព្រាងច្បាប់ទៅស្ថាប័ននីតិប្បញ្ញត្តិចំនួន១៣៧។ ច្បាប់ដែលស្ថាប័ននីតិប្បញ្ញត្តិអនុម័តរួច ចំនួន៧៧ច្បាប់ ក្នុងនោះមានច្បាប់សម្រាប់យុត្តាធិការតុលាការនិងច្បាប់សំខាន់ៗតាមវិស័យផ្សេងៗទៀតមានជាអាទិ៍៖

-ច្បាប់ស្ដីពីកិច្ចការពារនិងលើកកម្ពស់ជនពិការ (ប្រកាសឲ្យប្រើថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩)

-ក្រមព្រហ្មទណ្ឌ (ប្រកាសឲ្យប្រើថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩)

-ច្បាប់ស្ដីពីការធ្វើបាតុកម្មដោយសន្តិវិធី(ប្រកាសឲ្យប្រើថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ២០០៩)

-ច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ (ប្រកាសឲ្យប្រើថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០១០)

-ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល(ប្រកាសឲ្យប្រើថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០)

-ច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង (ប្រកាសឲ្យប្រើថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០១០)

-ច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី (ប្រកាសឲ្យប្រើថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១)

-ច្បាប់ស្ដីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋបាលថ្នាក់ក្រោមជាតិ (ប្រកាសឲ្យប្រើថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១)

-ច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ(ប្រកាសឲ្យប្រើថ្ងៃទី០១ ខែសីហា ឆ្នាំ ២០១១)

-ច្បាប់ស្ដីពីពន្ធនាគារ (ប្រកាសឲ្យប្រើថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១)

-ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន(ប្រកាសឲ្យប្រើថ្ងៃទី០១ ខែមករា ឆ្នាំ២០១២)

-ច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ (ប្រកាសឲ្យប្រើថ្ងៃទី០២ ខែមករា ឆ្នាំ២០១២)

## ចៅក្រម

រហូតមកដល់ដំណាច់ឆ្នាំ២០១២នេះ ចំនួនចៅក្រមសរុបនៅទូទាំងប្រទេស ដែលបានបញ្ចប់ការបណ្តុះបណ្តាលដោយជោគជ័យពីរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មានចំនួន ៤២៥នាក់ ក្នុងនោះមានចៅក្រមអាសនៈ ២៨០នាក់ និងចៅក្រមអយ្យការ ១៤៥នាក់។ ប៉ុន្តែ ចំនួនជាក់ស្តែងនៃចៅក្រមដែលកំពុងបំពេញមុខងារក្នុងពេលបច្ចុប្បន្ន មានចំនួន ៤០៣នាក់ ក្នុងនោះ មានចៅក្រមអាសនៈ ២៦៣នាក់ និងចៅក្រមអយ្យការ ១៤០នាក់។

## ក្រឡាបញ្ជី

រហូតមកដល់ដំណាច់ឆ្នាំ២០១២នេះ ចំនួនក្រឡាបញ្ជីសរុបនៅទូទាំងប្រទេស ដែលបានបញ្ចប់ការបណ្តុះបណ្តាលដោយជោគជ័យពីរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មានចំនួន ៧៣៤នាក់ ។ ប៉ុន្តែ ចំនួនជាក់ស្តែងនៃក្រឡាបញ្ជីដែលកំពុងបំពេញមុខងារក្នុងពេលបច្ចុប្បន្ន មានចំនួន ៦១៥នាក់។

## មេធាវី

រហូតមកដល់ដំណាច់ឆ្នាំ២០១២នេះ ចំនួនមេធាវីសរុបនៅទូទាំងប្រទេស មាន ៨១៨នាក់ (ស្រី ១៤៧នាក់)។ ដោយឡែកនៅឆ្នាំ២០១២នេះ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី បានបណ្តុះបណ្តាលមេធាវីចំនួន៥៩នាក់។

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក.)** ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ បានបញ្ចប់សំណុំរឿង ០០១ និងកំពុងដំណើរការលើសំណុំរឿង០០២ ដែលមានពិរុទ្ធជនចំនួន០៤រូប ជាមេដឹកនាំជាន់ខ្ពស់បំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះវិសាមញ្ញនេះ បានចាប់ផ្តើមដំណើរការតាំងពីខែកុម្ភៈ ឆ្នាំ២០០៦មកនិងបានចំណាយថវិកាអស់ ១៧០លានដុល្លារអាមេរិក។

## ៣-កំណែទម្រង់រដ្ឋបាលសាធារណៈ

### ក-ការគ្រប់គ្រងក្របខ័ណ្ឌ

*ក្នុងរយៈពេល៥ឆ្នាំ គិតពីឆ្នាំ២០០៨ដល់ឆ្នាំ២០១២ ក្របខ័ណ្ឌគ្រប់ក្រសួង ស្ថាប័នសម្រេចបានលទ្ធផលដូចខាងក្រោម៖*

*-ជ្រើសរើសមន្ត្រីរាជការស៊ីវិលចូលក្របខ័ណ្ឌ បានចំនួន ៣៧ ៨០២នាក់។*

*-ដាក់ឱ្យចូលនិវត្តន៍មន្ត្រីរាជការស៊ីវិល បានចំនួន ១១ ៩៩៣នាក់។*

*-ផ្តល់សលាកបត្រព័ត៌មានមន្ត្រីរាជការស៊ីវិលនិងរៀបចំបែបបទបញ្ចូលទិន្នន័យមន្ត្រីក្របខ័ណ្ឌថ្មីបានចំនួន ៤១ ៧១១នាក់។*

*-រៀបចំព្រះរាជក្រឹត្យនិងអនុក្រឹត្យតាំងស៊ប់ក្នុងក្របខ័ណ្ឌបានចំនួន១៩ ២៦៩នាក់។*

-រៀបចំព្រះរាជក្រឹត្យនិងអនុក្រឹត្យដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍បានចំនួន ៤៧៧នាក់។

-រៀបចំព្រះរាជក្រឹត្យនិងអនុក្រឹត្យដំឡើងឋានន្តរសក្តិនិងថ្នាក់បានចំនួន ៦ ៣៦៥នាក់។

-ដោយឡែកមន្ត្រីរាជការស៊ីវិលនៅទូទាំងប្រទេសក្នុងតារាងទូទាត់បៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យាខែធ្នូ ឆ្នាំ២០១២ មានចំនួនសរុប ១៨១ ៩៣០នាក់(ស្ត្រី៦៥ ៨៨៨នាក់) ស្មើនឹង៣៦% ក្នុងនោះមន្ត្រីរាជការនៅថ្នាក់ជាតិ មានចំនួន ៣៣ ១០៦នាក់ស្មើនឹង ១៨,២% និងថ្នាក់ក្រោមជាតិចំនួន ១៤៨ ៨២៤នាក់ ស្មើនឹង ៨១,៨%។

## ខ-ការរៀបចំបៀវត្សមន្ត្រីរាជការ

រាជរដ្ឋាភិបាល បានសម្រេចដំឡើងប្រាក់បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការចំនួន ២០%ក្នុងមួយឆ្នាំ ចាប់តាំងពីឆ្នាំ២០០៨ដល់ឆ្នាំ២០១៣។ ដោយឡែកក្នុងឆ្នាំ២០១២ តម្លៃឯកតានៃសន្ទស្សន៍ស្មើនឹង ១ ២៦០រៀល ធ្វើឲ្យបៀវត្សមូលដ្ឋានបានកើនឡើងប្រមាណ ៤ដងបើធៀបនឹងខែមករា ឆ្នាំ២០០២ ដែលមានតម្លៃតែ៣០០រៀល ក្នុងមួយសន្ទស្សន៍។ នៅក្នុងឆ្នាំ២០១២នេះ បៀវត្សមធ្យមរបស់មន្ត្រីរាជការស៊ីវិលបានកើនឡើងដល់ ៤២៧ ៧០៧ រៀល ក្នុងមួយខែ ដែលកំណើននេះស្មើនឹង៧៧៧,៣% បើធៀបនឹងខែតុលា ឆ្នាំ២០០១ (កាលពី១១ឆ្នាំមុន)។ បៀវត្សអប្បបរមា(ក្របខ័ណ្ឌឃ.៣.១៤)មានចំនួន ១២៦ ០០០រៀល ក្នុងមួយខែ បានកើនឡើងចំនួន ៣៧០% បើធៀបនឹងខែតុលា ឆ្នាំ២០០១ មានតែត្រឹមតែ២៦ ៨៦០រៀល។ បៀវត្សអគ្គនាយកនៃក្រសួង ស្ថាប័ន (ក្របខ័ណ្ឌក.១.១) មានចំនួន ១ ៦២២ ០០០រៀល ក្នុងមួយខែ បានកើនឡើង១ ៨៩៤% បើធៀបនឹងខែតុលា ឆ្នាំ ២០០១ ដែលមានចំនួន ៨៤ ៥៩០រៀល។

គ្រូបង្រៀនកម្រិតឧត្តមសិក្សា (ក.២.១) មានបៀវត្សចំនួន ៨៩០ ០០០ រៀល ក្នុងមួយខែ បានកើនឡើង ៦០៣% បើធៀបនឹងខែតុលា ឆ្នាំ២០០១ មាន ១៣៧ ៧៥០រៀល។ គ្រូបង្រៀនបឋមសិក្សាដែលមានកម្រិតសន្ទស្សន៍ទាបបំផុតមានបៀវត្ស(គ.៣.១៤) ២៧១ ៨០០ រៀលក្នុងមួយខែ បានកើនឡើង ២០០% បើធៀបនឹងខែតុលា ឆ្នាំ២០០១ មានតែ ៩០ ៤០០ រៀល។ គ្រូបង្រៀនបឋមសិក្សាខ្ពស់បំផុត (គ.១.១) មានបៀវត្សចំនួន ៣៩៣ ៣១០ រៀល ក្នុងមួយខែ បានកើនឡើងចំនួន ២៥៨,៣% បើធៀបនឹងខែតុលា ឆ្នាំ២០០១ មានតែ ១០៩ ៧៨០ រៀល។ តួលេខខាងលើនេះ មិនទាន់បានគិតបញ្ចូលនូវប្រាក់តំបន់ ប្រាក់ប៉ះពាល់សុខភាព ប្រាក់ឧបត្ថម្ភប្រពន្ធ និងប្រាក់ឧបត្ថម្ភកូនក្នុងបន្ទុកនៅឡើយទេ។

## គ- ការងារវិមជ្ឈការនិងវិសហមជ្ឈការ

### ☆ការអភិវឌ្ឍថ្នាក់ក្រោមជាតិ

- ពីឆ្នាំ២០០២ ដល់ឆ្នាំ២០០៧ រាជរដ្ឋាភិបាលបានផ្តល់ការគាំទ្រដល់មូលនិធិឃុំ សង្កាត់ ជាមធ្យម ពី៩ ០០០(ប្រាំបួនពាន់) ដល់១០ ០០០(ដប់ពាន់) ដុល្លារអាមេរិកក្នុងមួយឆ្នាំ សម្រាប់គម្រោង

អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ គម្រោងអភិវឌ្ឍន៍សង្គម និងការផ្តល់សេវាកម្មជូនប្រជាពលរដ្ឋ រួមចំណែកកាត់បន្ថយភាពក្រីក្រ។

- ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១២ នេះ រាជរដ្ឋាភិបាលបានផ្តល់ការគាំទ្រដល់មូលនិធិឃុំ សង្កាត់ ជាមធ្យមប្រមាណពី ១៥ ០០០ (ដប់ប្រាំពាន់) ទៅ ២៤ ០០០ (ម្ភៃបួនពាន់) ដុល្លារអាមេរិក ក្នុងមួយឆ្នាំសម្រាប់អភិវឌ្ឍ និងផ្តល់សេវាកម្មជូនប្រជាពលរដ្ឋបន្តរួមចំណែកកាត់បន្ថយភាពក្រីក្រ។
- រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ៦៨អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងគោលបំណងធានានូវការផ្តល់សេវានៅរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយគុណភាព តម្លាភាព ប្រសិទ្ធភាព និងឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងធុរជន។

**ឃ-ការធានាប្រជាធិបតេយ្យនីយកម្ម**

- **ចំនួនគណបក្ស**

គិតត្រឹមដំណាច់ឆ្នាំ២០១២នេះ គណបក្សនយោបាយមានចំនួន ៥៦គណបក្ស ក្នុងនោះ បានចុះបញ្ជីនៅក្រសួងមហាផ្ទៃ ៤២គណបក្ស ។

- **លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ លើកទី១**

ត្រូវបានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ផ្សព្វផ្សាយកាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ មានដូចខាងក្រោម ៖

☞សំឡេងឆ្នោត និងអាសនៈនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត គណបក្សនាំមុខគេគឺ៖

-គណបក្សប្រជាជនកម្ពុជា បានទទួលការគាំទ្រ ៨ ៥៤៥សំឡេង ទទួលបានជាប្រធានក្រុមប្រឹក្សារាជធានី ខេត្ត២៤នាក់ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ២៧៨នាក់ ស្មើនឹង ៣០២អាសនៈ។

-គណបក្សសមរង្ស៊ី បានទទួលការគាំទ្រ ២ ៣១៧សំឡេង ទទួលបានជាសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ៦១នាក់ ស្មើនឹង ៦១អាសនៈ។

-គណបក្សហ៊្វុនស៊ិនប៉ិច បានទទួលការគាំទ្រ ២៣៦សំឡេង ទទួលបានជាសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ០៦នាក់ ស្មើនឹង ០៦អាសនៈ។

-គណបក្សនរោត្តម រណឫទ្ធិ បានទទួលការគាំទ្រ ២៣១សំឡេង ទទួលបានជាសមាជិកក្រុមប្រឹក្សា រាជធានី ខេត្ត ០៥នាក់ ស្មើនឹង ០៥អាសនៈ។

☞សម្លេងឆ្នោត និងអាសនៈនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ គណបក្សនាំមុខគេគឺ៖

-គណបក្សប្រជាជនកម្ពុជា បានទទួលការគាំទ្រ ៨ ៤៧៣សំឡេង ទទួលបានជាប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ១៩៣នាក់ ជាសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ២ ០៥៦នាក់ ស្មើនឹង ២ ២៤៩អាសនៈ។

-គណបក្សសមរង្ស៊ី បានទទួលការគាំទ្រ ២ ៣៣២សំឡេង ទទួលបានជាសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ៥១៨នាក់ ស្មើនឹង ៥១៨អាសនៈ។

-គណបក្សហ៊្វុនស៊ិនប៉ិច បានទទួលការគាំទ្រ ២៦២សំឡេង ទទួលបានជាសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ៥៥នាក់ ស្មើនឹង ៥៥អាសនៈ។

-គណបក្សនរោត្តម រណឫទ្ធិ បានទទួលការគាំទ្រ ២៦៤សំឡេង ទទួលបានជាសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ៣៩នាក់ ស្មើនឹង ៣៩អាសនៈ។

**•លទ្ធផលនៃការបោះឆ្នោតឡើងវិញ ដើម្បីជ្រើសរើសសមាជិកក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃអាទិត្យ ទី១១ ខែ ធ្នូ ឆ្នាំ២០១១**

-គណបក្សប្រជាជនកម្ពុជា បានទទួលការគាំទ្រ ៦៧សំឡេង ទទួលបានជាប្រធានក្រុមប្រឹក្សា ០១នាក់ សមាជិក ១៤នាក់ (ស្រី០១នាក់) ស្មើនឹង ១៥អាសនៈ។

-គណបក្សសមរង្ស៊ីបានទទួលការគាំទ្រ ២២សំឡេង ទទួលបានជាសមាជិកក្រុមប្រឹក្សា ០៤នាក់ ស្មើនឹង ០៤អាសនៈ។

**•លទ្ធផលនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៣**

មានគណបក្សនយោបាយចូលរួម ២គណបក្ស គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សសមរង្ស៊ី ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃអាទិត្យ ទី២៩ ខែមករា ឆ្នាំ២០១២។ លទ្ធផលគឺ គណបក្សប្រជាជនកម្ពុជា បានទទួលការគាំទ្រ ៨ ៨៨០សំឡេង ស្មើនឹង ៤៦អាសនៈ និងគណបក្សសមរង្ស៊ី បានទទួលការគាំទ្រ ២ ៥០៣សំឡេង ស្មើនឹង ១១អាសនៈ។

**•លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ (២០១២-២០១៧)**

តាមរបាយការណ៍របស់គ.ជ.ប បានឲ្យដឹងថា លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ (២០១២-២០១៧) ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃអាទិត្យ ទី០៣ ខែមិថុនា ឆ្នាំ២០១២ ហើយត្រូវបានប្រកាសជាផ្លូវការកាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១២ ដោយបានបង្ហាញថា ក្នុងឃុំ សង្កាត់ទាំង ១ ៦៣៣ មានគណបក្សចំនួន ០៧ប៉ុណ្ណោះ ដែលបានជាប់ឆ្នោត និងទទួលបានអាសនៈ នៅក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ ជាតំណែងមេឃុំ ឬចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ គឺ៖

-គណបក្សប្រជាជនកម្ពុជា បាននាំមុខក្នុងឃុំ សង្កាត់ ចំនួន ១ ៥៩២ និងទទួលបានអាសនៈ ៨ ២៩២អាសនៈ។

-គណបក្ស សម រង្ស៊ី បាននាំមុខក្នុងឃុំ សង្កាត់ ចំនួន២២ និងទទួលបានអាសនៈ ២ ១៥៥អាសនៈ។

-គណបក្ស សិទ្ធិមនុស្ស បាននាំមុខក្នុងឃុំ សង្កាត់ ចំនួន១៨ និងទទួលបានអាសនៈ ៨០០ អាសនៈ។

-គណបក្សហ៊្វុនស៊ិនប៉ិច បាននាំមុខក្នុងឃុំ សង្កាត់ ចំនួន០១ និងទទួលបានអាសនៈ ១៥១អាសនៈ។

-គណបក្សនរោត្តម រណឫទ្ធិ ទទួលបានអាសនៈ ៥២អាសនៈ។

-គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ទទួលបានអាសនៈ ០៨អាសនៈ។

-គណបក្សសញ្ជាតិកម្ពុជា ទទួលបានអាសនៈ ០១អាសនៈ។

☞លទ្ធផលគិតជាសំឡេងគាំទ្រដែលគណបក្សនីមួយៗ បានទទួលគឺ ៖

| | |
|---|---|
| -គណបក្សប្រជាជនកម្ពុជា | ៣ ៦៣១ ០៨២សំឡេង។ |
| -គណបក្សសម រង្ស៊ី | ១ ២២៤ ៤៦០សំឡេង។ |
| -គណបក្សសិទ្ធិមនុស្ស | ៥៨០ ៤៨៣សំឡេង។ |
| -គណបក្សហ៊្វុនស៊ិនប៉ិច | ២២២ ៦៦៣សំឡេង។ |
| -គណបក្សនរោត្តម រណឫទ្ធិ | ១៧០ ៩៦២សំឡេង។ |
| -គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ២៦ ៩១៦សំឡេង។ |
| -គណបក្សសញ្ជាតិកម្ពុជា | ១៦ ៦១៦សំឡេង។ |
| -គណបក្សខ្មែរឈប់ក្រ | ១ ៩៤០សំឡេង។ |
| -គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ | ៤៨៩សំឡេង។ |
| -គណបក្សចលនាប្រជាធិបតេយ្យ | ១០៨សំឡេង។ |

☞ក្នុងចំណោមសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាប់ឆ្នោតសរុប ១១ ៤៥៩អាសនៈ មានសមាជិកជាស្ត្រីចំនួន ២ ០៣៨នាក់ ស្មើនឹង ១៧,៧៨%។ ដោយឡែកការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី២ (២០០៧-២០១២) ក្នុងចំណោមសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាប់ឆ្នោតសរុប ១១ ៣៥៣ អាសនៈ មានសមាជិកជាស្ត្រីចំនួន ១ ៦៦១ នាក់ ស្មើនឹង ១៤,៦៣%។

### ខ-សង្គមស៊ីវិល

គិតមកដល់ដំណាច់ឆ្នាំ២០១២នេះ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ មាន ៣ ៤៤៩ ក្នុងនោះ សមាគម ១ ៣៧៥ និងអង្គការមិនមែនរដ្ឋាភិបាល ២ ០៧៤។

## ❖សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម

សភាពការណ៍សន្តិសុខនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ពុំមានបញ្ហាអ្វីដែលគួរឲ្យកត់សម្គាល់ឡើយ ក៏ប៉ុន្តែនៅតាមតំបន់ព្រំដែនកម្ពុជា-ថៃ មានការកើតឡើងនូវជម្លោះព្រំដែន ដែលទាហានថៃបានបង្កឡើងនៅតំបន់ប្រាសាទព្រះវិហារ និងតំបន់មួយចំនួនទៀត ចាប់ផ្តើមពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៨ ក្រោយពេលដែលប្រាសាទព្រះវិហាររបស់កម្ពុជា ត្រូវបានដាក់បញ្ចូលជាសម្បត្តិបេតិកភណ្ឌពិភពលោកនៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៨។ កងកម្លាំងប្រដាប់អាវុធនៃព្រះរាជាណាចក្រកម្ពុជា ការពារបូរណភាពទឹកដីបានយ៉ាងរឹងមាំ ហើយជម្លោះនេះមានសភាពធូរស្រាល ក្រោយពេលប្រទេសថៃមានរដ្ឋាភិបាលថ្មី ដែលដឹកនាំដោយគណបក្សភឿថៃ។ ស្ថានការណ៍នៅតាមព្រំដែនបានវិលមករកភាពស្ងប់ស្ងាត់វិញ ទំនាក់ទំនងរវាងយោធាទាំងពីរប្រទេស ពិសេសនៅតំបន់ព្រំដែនមានភាពប្រសើរឡើង ជីវភាពប្រជាជនក៏បានវិលមករកភាពប្រក្រតីវិញដែរ។ ទន្ទឹមនេះ រាល់យន្តការដោះស្រាយបញ្ហាព្រំដែន ក៏កំពុងត្រូវបានជំរុញប្រកបដោយភាពវិជ្ជមាន។

**♦ការងារចុះបញ្ជីគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋ**

គិតត្រឹមខែកក្កដា ឆ្នាំ២០១២ បានផ្តល់សៀវភៅស្នាក់នៅចំនួន ២ ៥៨១ ៦២៩គ្រួសារ និងសៀវភៅគ្រួសារចំនួន ២ ៥២៣ ៧២៥គ្រួសារ ផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរជូនប្រជាពលរដ្ឋបាន ៨ ៦៦៩ ០៦៣នាក់ លើចំនួនដែលត្រូវផ្តល់ ៩ ៦៣៥ ៧២៥នាក់។

**♦ គ្រោះថ្នាក់ចរាចរ**

| បរិយាយ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ត្រីមាសទី១ ឆ្នាំ ២០១៣ |
|---|---|---|---|---|---|
| គ្រោះថ្នាក់ចរាចរ(លើក) | ៦ ០២១ | ៥ ៤៣០ | ៥ ០៩៦ | ៤ ៣០៥ | ១ ១៦៣ |
| ស្លាប់ (នាក់) | ១ ៦៥៤ | ១ ៦៣៧ | ១ ៨៩៥ | ១ ៨៩៤ | ៥៤០ |
| របួសធ្ងន់ និងស្រាល (នាក់) | ១០ ៣១០ | ៩ ៣៩៣ | ៨ ៧៣៩ | ៧ ៤៦៧ | ១ ៨៩៧ |

## សមាហរណកម្មកម្ពុជានៅក្នុងតំបន់និងពិភពលោក

♦ព្រះរាជាណាចក្រកម្ពុជា បានចូលជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ នៅទីក្រុងហាណូយ សាធារណរដ្ឋសង្គមនិយមវៀតណាម។ នៅឆ្នាំ២០១២នេះ ព្រះរាជាណាចក្រកម្ពុជា បានធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធ បន្ទាប់ពីបានធ្វើជាប្រធានអាស៊ានលើកទី១ នៅឆ្នាំ២០០២។

♦ព្រះរាជាណាចក្រកម្ពុជា បានចូលជាសមាជិកនៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោក ក្នុងមហាសន្និបាតលើកទី១៧របស់រដ្ឋភាគីទាំង១៨៦ នៃអនុសញ្ញាឆ្នាំ១៩៧២ ស្តីពីកិច្ចការពារ

បេតិកភណ្ឌវប្បធម៌និងធម្មជាតិពិភពលោក ដែលបានប្រារព្ធធ្វើក្នុងសន្និសីទលើកទី៣៥ នៃអង្គការយូណេស្កូ (UNESCO) នាទីក្រុងប៉ារីស សាធារណរដ្ឋបារាំង កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៩។ ព្រះរាជាណាចក្រកម្ពុជាទទួលធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំគណៈកម្មាធិការបេតិកភណ្ឌពិភពលោក នៅឆ្នាំ២០១៣នេះ។

- រាជរដ្ឋាភិបាលកម្ពុជា បានបន្តអនុវត្តដោយជោគជ័យនូវសមាហរណកម្មកម្ពុជា ចូលក្នុងសហគមន៍អន្តរជាតិ ទាំងក្នុងក្របខ័ណ្ឌអនុតំបន់ តំបន់ និងពិភពលោក។ រហូតមកដល់បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជា មានទំនាក់ទំនងការទូតជាមួយប្រទេសជាមិត្តចំនួន ១៥៨ ប្រទេស។ ស្ថានទូតបរទេសនៅរាជធានីភ្នំពេញសរុបទាំងអស់មាន ចំនួន២៦ ។ ប្រទេសចំនួន៧០ បានតែងតាំងឯកអគ្គរាជទូត/រដ្ឋទូតប្រចាំកម្ពុជា ប៉ុន្តែមាននិវេសនដ្ឋាននៅក្រៅប្រទេស។ ស្ថានឯកអគ្គរាជទូត និងស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជាប្រចាំនៅបរទេស សរុបមានចំនួន ២៦។

- *រាជរដ្ឋាភិបាលកម្ពុជាបានបញ្ជូនកងយោធពលខេមរភូមិន្ទ ចំនួន ១០លើក មានចំនួន ១ ៤៤២នាក់ ចូលរួមជាមួយកងកម្លាំងរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិនៅក្នុងប្រទេសស៊ូដង់ ស៊ូដង់ខាងត្បូង ឆាត អាហ្វ្រិកកណ្តាល លីបង់ និងស៊ីរី លើជំនាញបោសសំអាតមីន វិស្វកម្មតម្រួតសណ្តាប់ធ្នាប់ កងរាជអាវុធហត្ថ ពេទ្យកម្រិត២ និងនាយទាហានសេនាធិការ និងសង្កេតការណ៍ ដោយទទួលបានការគាំទ្របច្ចេកទេសហ្វឹកហ្វឺន ពីបណ្តាប្រទេសជាមិត្តដូចជា សហរដ្ឋអាមេរិក ចិន អង់គ្លេស កាណាដា ឥណ្ឌា បារាំង អូស្ត្រាលី អាល្លឺម៉ង់ ជប៉ុន និងបណ្តាអង្គការអន្តរជាតិនិយាយភាសាបារាំង* ( Franco Phonies ) ។

## ☼ការងារព្រំដែន

### *ក- ជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម*

| សរុបសមិទ្ធផល ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១២ | | | | | ស្ថានភាព សូចនាករបច្ចុប្បន្ន ២០១៣ | គោលដៅសូចនាករ ចុងក្រោយ |
|---|---|---|---|---|---|---|
| បោះបង្គោល | | ខណ្ឌសីមា | | | | |
| ទីតាំង | លើដី | គ.ម. | ទីតាំង | លើដី | | |
| ២០៥ | ២៣៩ | ៨៤៦ | ៧៧៨ | ៩០៩ | បន្តចរចារកដំណោះស្រាយលើបញ្ហាសេសសល់ និងបន្តខណ្ឌសីមា និងបោះបង្គោល | មានខ្សែព្រំដែនច្បាស់លាស់ទាំងលើផែនទី និងលើដីជាក់ស្តែង។ មានបង្គោលព្រំដែនទុកជាអចិន្ត្រៃយ៍។ គ្មានជម្លោះព្រំដែន។ |

### ខ- ជាមួយសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

| សរុបសមិទ្ធផលពីឆ្នាំ ២០០៨ដល់២០១២ | ស្ថានភាពសូចនាករបច្ចុប្បន្ន ២០១៣ | គោលដៅសូចនាករចុងក្រោយ |
|---|---|---|
| | បន្តការចរចារកដំណោះស្រាយលើបញ្ហារាំងស្ទះជាបន្តទៀត និងបន្តបោះបង្គោលខណ្ឌសីមា | មានខ្សែព្រំដែនច្បាស់លាស់ទាំងលើផែនទី និងលើដីជាក់ស្តែង ប្រែក្លាយពីព្រំដែនរដ្ឋបាលទៅជាព្រំដែនអន្តរជាតិ ។ មានបង្គោលព្រំដែន និងផែនទីទុកជាអចិន្ត្រៃយ៍។ គ្មានជម្លោះព្រំដែន។ ដើម្បីភាពសុខសាន្តរបស់ប្រទេសជាតិតរៀងទៅ។ |

### គ- ជាមួយព្រះរាជាណាចក្រថៃឡង់ដ៍

| សរុបសមិទ្ធផលពីឆ្នាំ ២០០៨ដល់២០១២ | ស្ថានភាពសូចនាករបច្ចុប្បន្ន ២០១៣ | គោលដៅសូចនាករចុងក្រោយ |
|---|---|---|
| រុករកបង្គោលចាស់ ២៣ | បន្តការចរចារកដំណោះស្រាយលើបញ្ហារាំងស្ទះជាបន្តទៀត និងបន្តរុករកបង្គោលដែលនៅសល់ | មានខ្សែព្រំដែនច្បាស់លាស់ដូចអន្តរជាតិបានបន្សល់ទុកឲ្យ។ គ្មានជម្លោះព្រំដែន។ ដើម្បីភាពសុខសាន្តរបស់ប្រទេសជាតិតរៀងទៅ។ |

### ❖ច្រកទ្វារអន្តរជាតិ ( ស្ថិតនៅផ្ទៃក្នុងព្រះរាជាណាចក្រកម្ពុជា )

១-អាកាសយានដ្ឋានអន្តរជាតិមាន៣ គឺ អាកាសយានអន្តរជាតិភ្នំពេញ អាកាសយានដ្ឋានអន្តរជាតិសៀមរាប និងអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ ។

២-កំពង់ផែអន្តរជាតិមាន០២គឺ៖ កំពង់ផែស្វយ័តក្រុងព្រះសីហនុ និងកំពង់ផែស្វយ័តភ្នំពេញ។

៣-កំពង់ផែសមុទ្រ មាន៖ កំពង់ផែទំនប់រលក ស្ទឹងហាវ កែវផុស ស្រែអំបិល ក្រុងកំពតប៉ាក់ខ្លង និងកំពង់ផែកែប។

### ❖ច្រកទ្វារព្រំដែនអន្តរជាតិ ( ស្ថិតនៅតាមព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជានិងប្រទេសជិតខាង )

| ល.រ. | ឈ្មោះច្រកទ្វារព្រំដែនអន្តរជាតិ | ខេត្ត |
|---|---|---|
| ១ | ចាំយាម | កោះកុង |
| ២ | ប៉ោយប៉ែត | បន្ទាយមានជ័យ |
| ៣ | ដូង | បាត់ដំបង |

| | | |
|---|---|---|
| ៤ | ព្រំ | ប៉ៃលិន |
| ៥ | អូរស្មាច់ | ឧត្តរមានជ័យ |
| ៦ | ជាំ | |
| ៧ | ត្រពាំងក្រៀល | ស្ទឹងត្រែង |
| ៨ | អូរយ៉ាដាវ | រតនគិរី |
| ៩ | ត្រពាំងស្រែ | ក្រចេះ |
| ១០ | ត្រពាំងផ្លុង | កំពង់ចាម |
| ១១ | បាវិត | ស្វាយរៀង |
| ១២ | សំរោង | |
| ១៣ | ព្រៃវល្លិ៍ | |
| ១៤ | ក្អមសំណ | កណ្ដាល |
| ១៥ | បន្ទាយចក្រី | ព្រៃវែង |
| ១៦ | ភ្នំដិន | តាកែវ |
| ១៧ | ព្រែកចាក | កំពត |

## បរិស្ថានម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ(២០០៨-២០១២)

- កំណើនសេដ្ឋកិច្ចជាមធ្យមសម្រេចបាន ៥,៤%ក្នុងមួយឆ្នាំ។ ប៉ុន្តែ បើមិនរាប់បញ្ចូលកំណើនឆ្នាំ ២០០៩ ដែលជាឆ្នាំនៃការធ្លាក់ចុះនៃវិបត្តិសេដ្ឋកិច្ចសាកល កំណើនសេដ្ឋកិច្ចកម្ពុជា សម្រេចបានជាមធ្យម ៦,៨% ដោយគណនាថា កំណើនសេដ្ឋកិច្ចនៅឆ្នាំ ២០១២ នឹងសម្រេចបាន ៧,៣% (ទល់នឹងការគ្រោងទុក ៦,៥%) និង ៧% នៅក្នុងឆ្នាំ ២០១៣។ លទ្ធផលនេះបានមកពីកំណើនក្នុងវិស័យកសិកម្ម ៤,១% វិស័យឧស្សាហកម្មកាត់ដេរ ៧,៧% និងវិស័យសេវាកម្មទេសចរណ៍ ៥,៤%។

### ផលិតផលសរុបក្នុងស្រុក (GDP)

| ២០០៦ | ២០០៧ | ២០០៨ |
|---|---|---|
| ១០,៨% | ១០,២% | ៦,៧% |

| ២០០៩ | ២០១០ | ២០១១ | ២០១២ |
|---|---|---|---|
| ០,១% | ៦% | ៧,១% | ៧,៣% |

- ផលិតផលក្នុងស្រុកសរុប(ផសស) សម្រាប់មនុស្សម្នាក់បានកើនឡើងពី ៧៦០ដុល្លារអាមេរិក នៅក្នុងឆ្នាំ២០០៨ ដល់ជិត ១ ០០០ដុល្លារអាមេរិក នៅក្នុងឆ្នាំ២០១២ ហើយរំពឹងថា នឹងអាចឡើងជាង ១ ០០០ដុល្លារអាមេរិក នៅក្នុងឆ្នាំ២០១៣ ដែលនឹងធ្វើឲ្យកម្ពុជាឈានឡើងជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងរយៈពេលមិនយូរខាងមុខនេះ។

អត្រានៃភាពក្រីក្របានធ្លាក់ចុះពី ២២,៩% នៅក្នុងឆ្នាំ២០០៩ មកត្រឹម ២០% នៅក្នុងឆ្នាំ២០១២ ហើយរំពឹងថា អាចនឹងចុះមកត្រឹម ១៩% នៅឆ្នាំ ២០១៣។

តាមរយៈលទ្ធផលនេះ កម្ពុជាត្រូវបានវាយតម្លៃថា ជាប្រទេសស្ថិតក្នុងចំណាត់ថ្នាក់ទី១៥ ដែលសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់លើពិភពលោក ក្នុងរយៈពេល១០ឆ្នាំចុងក្រោយ ជាប្រទេសស្ថិតក្នុងចំណាត់ថ្នាក់ទី៥ ក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍ ដែលនឹងអាចសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្ស និងជាប្រទេសមានចំណាត់ថ្នាក់ទី១នៅអាស៊ីប៉ាស៊ីហ្វិក ដែលបានសម្រេចវឌ្ឍនភាពដ៏ល្អប្រសើរ ក្នុងការកែលម្អសូចនាករផ្នែកសង្គមកិច្ច។

- ប្រភពចំណូលសំខាន់នៅព្រះរាជាណាចក្រកម្ពុជា គឺពន្ធលើប្រាក់ចំណេញ (ពន្ធផ្ទាល់) ពន្ធនាំចូល ពន្ធនាំចេញ ពន្ធលើតម្លៃបន្ថែម ពន្ធពិសេស (ពន្ធមិនផ្ទាល់ទាំងអស់) និងចំណូលមិនមែនសារពើពន្ធ។
- អតិផរណាត្រូវបានរក្សាឲ្យបន្តស្ថិតនៅក្នុងកម្រិតដែលអាចគ្រប់គ្រងបានជាបន្តបន្ទាប់។ ជាក់ស្តែង អត្រាអតិផរណាមានកម្រិតខ្ពស់ ១៩,៧% នៅក្នុងឆ្នាំ២០០៨ ត្រូវបានគ្រប់គ្រងឲ្យមកស្ថិតនៅក្នុងរង្វង់ក្រោម ១% នៅក្នុងឆ្នាំ២០០៩ និងក្នុងរង្វង់ ៥% រហូតមកទល់នឹងឆ្នាំ២០១២។ អត្រាអតិផរណារំពឹងថា នឹងចុះមកត្រឹម ៤% នៅក្នុងឆ្នាំ ២០១៣។

## ❖ការគ្រប់គ្រងពាណិជ្ជកម្ម

- ទំនិញនាំចេញសំខាន់ៗរបស់ព្រះរាជាណាចក្រកម្ពុជា គឺសម្លៀកបំពាក់ និងផលិតផលកសិកម្ម ដែលមានប្រភពធនធានពីកសិកម្ម(ស្រូវ អង្ករ ត្រី និងកៅស៊ូ)។ ទំនិញនាំចេញសំខាន់ៗទាំងនោះបានទទួលរងផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិភពលោកក្នុងឆ្នាំ២០០៩ ដោយសារការធ្លាក់ចុះនៃតម្រូវការក្នុងទីផ្សារអន្តរជាតិ។ សមាសធាតុធំៗនៃផលិតផលនាំចូល រួមមាន វត្ថុធាតុដើម សម្រាប់កម្មន្តសាលសម្លៀកបំពាក់ និងវត្ថុធាតុដើមសម្រាប់សំណង់។
- សេដ្ឋកិច្ចកម្ពុជា គឺជាសេដ្ឋកិច្ចមួយបើកចំហ ដែលបានធ្វើឲ្យព្រះរាជាណាចក្រកម្ពុជា ក្លាយជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោកនៅឆ្នាំ២០០៤ ហើយបាននិងកំពុងអនុវត្តលក្ខខណ្ឌសេដ្ឋកិច្ចបើកចំហនេះ រហូតមកទល់ពេលបច្ចុប្បន្ន។

| សូចនាករ | ឯកតា | ២០០៩ | ២០១០ | ២០១១ | ២០១២ |
|---|---|---|---|---|---|
| ការនាំចេញ | ពាន់លានរៀល | ១២ ១៥៤ | ១៥ ៧៣៧ | ២០ ០១៤ | ២២ ៤៨១ |
| ការនាំចូល | ពាន់លានរៀល | ១៥ ៦៩៤ | ២០ ១៩៥ | ២៥ ៥៤៩ | ៣០ ៤៥៤ |
| ជញ្ជីងពាណិជ្ជកម្ម | ពាន់លានរៀល | -៣ ៥៤១ | -៤ ៤៥៧ | -៥ ៥៣៥ | -៧ ៩៧៣ |

- ទំហំពាណិជ្ជកម្មឆ្នាំ២០០៨ មានទឹកប្រាក់ ៨ ៧៧៦ លានដុល្លារអាមេរិក ក្នុងនោះការនាំចេញមាន ៤ ៣៥៩លានដុល្លារអាមេរិក នៅឆ្នាំ២០១២ ទំហំពាណិជ្ជកម្មបានកើនដល់ ១៣ ៦២៦ លានដុល្លារអាមេរិក ក្នុងនោះការនាំចេញមាន ៥ ៤៨៧ លានដុល្លារអាមេរិក។
- គិតត្រឹមឆ្នាំ២០០៨ ក្រុមហ៊ុន ការិយាល័យតំណាងក្រុមហ៊ុន និងសាខាក្រុមហ៊ុនបរទេសមានចំនួន ២១ ២២៨ និងសហគ្រាសឯកបុគ្គល មានចំនួន ៤ ២៩៥។ ចំនួននេះ បានកើនឡើង

ជាបន្តបន្ទាប់ ដែលគិតមកដល់ដំណាច់ឆ្នាំ២០១២នេះ មាន ក្រុមហ៊ុន ការិយាល័យតំណាង ក្រុមហ៊ុន និងសាខាក្រុមហ៊ុនបរទេស មានចំនួន ៣០ ៥៧៤ កើនឡើង ១៤ ១២៣ សហគ្រាសឯកបុគ្គលមានចំនួន ៦ ៣៤៥ កើនឡើង ២ ៩៤២។ កំណើននេះ បាន បង្ហាញអំពីការជឿទុកចិត្តពីសំណាក់អាជីវករ ពាណិជ្ជករ ចំពោះស្ថានភាពពាណិជ្ជកម្ម ស្ថិរភាពទីផ្សារ និងស្ថិរភាពនយោបាយរបស់កម្ពុជា។

### ☼ប្រព័ន្ធធនាគារនៅកម្ពុជា (ឆ្នាំ២០០៨-២០១២)

| បរិយាយ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ |
|---|---|---|---|---|---|
| ធនាគារជាតិនៃកម្ពុជា | ១ | ១ | ១ | ១ | ១ |
| សាខាធនាគារជាតិនៃកម្ពុជា | ១៩ | ១៩ | ១៩ | ១៩ | ១៩ |
| ធនាគារពាណិជ្ជ | ២៤ | ២៧ | ២៩ | ៣១ | ៣២ |
| សាខាធនាគារពាណិជ្ជបរទេស | ៣ | ៥ | ៧ | ៩ | ៩ |
| បុត្តសម្ព័ន្ធធនាគារបរទេស | | | | ៩ | ១០ |
| ធនាគារពាណិជ្ជក្នុងស្រុក | ២១ | ២២ | ២២ | ១៣ | ១៣ |
| សាខាធនាគារពាណិជ្ជ រាជធានី ខេត្ត | ១០២ | ១២៩ | ១៤៧ | ១៧០ | ១៧១ |
| ការិយាល័យតំណាង ធនាគារបរទេស | ២ | ៣ | ២ | ២ | ៤ |
| ធនាគារឯកទេស | ៦ | ៦ | ៧ | ៧ | ៧ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានអាជ្ញាបណ្ណ | ១៨ | ២០ | ២៥ | ៣២ | ៣៥ |
| តូបដូរប្រាក់ | ៣ ៩៣៧ | ៣ ២៤៩ | ១ ៣៣៣ | ១ ៦៣២ | ១ ៦៤០ |

♦ក្នុងរយៈពេល០៥ឆ្នាំ(២០០៨-២០១២) តម្លៃប្រាក់រៀលធៀបនឹងដុល្លារអាមេរិកបានប្រែប្រួល ក្នុងរង្វង់ ៣ ៩៩១រៀល ទៅ ៤ ២៥៦ រៀល ក្នុង១ដុល្លារអាមេរិក ។ បើផ្អែកលើមូលដ្ឋាន មធ្យមឆ្នាំលើឆ្នាំ ប្រាក់រៀលបានឡើងថ្លៃជាមធ្យម ០,១% ពីដើមឆ្នាំ២០០៨ ដល់ខែធ្នូ

ឆ្នាំ២០១២។ ការឡើងថ្លៃប្រាក់រៀលនេះ បណ្ដាលមកពីកំណើនតម្រូវការប្រាក់រៀលសម្រាប់វិស័យឯកជន និងការធ្លាក់ថ្លៃជាសកលនៃប្រាក់ដុល្លារអាមេរិក។

- គិតត្រឹមខែធ្នូ ឆ្នាំ២០១២ ទុនបម្រុងអន្តរជាតិរបស់កម្ពុជាបានកើនដល់ ៣ ៤៦៣លានដុល្លារអាមេរិក គឺមានកំណើន៦០% បើធៀបនឹងចុងឆ្នាំ២០០៨ ដែលមាន ២ ១៦៤លានដុល្លារអាមេរិក និងកើនឡើងប្រមាណ ៨ដង បើធៀបនឹងឆ្នាំ១៩៩៨ ដែលមានត្រឹមតែ ៣៩០លានដុល្លារអាមេរិក។ ជារួមទុនបម្រុងអន្តរជាតិរបស់កម្ពុជា មានអត្រាកំណើនជាមធ្យមប្រមាណ ១៧% ក្នុងមួយឆ្នាំ។

## I-ការលើកស្ទួយវិស័យកសិកម្ម

### ១-ផលិតកម្មដំណាំស្រូវ

| ឆ្នាំ | បរិយាយ | | | | |
|---|---|---|---|---|---|
| | ផ្ទៃដីដំណាំស្រូវ( លានហិកតា) | | | ទិន្នផល (តោន/ហិកតា) | បរិមាណផល (លានតោន) |
| | ផែនការ | ដាំដុះ | ប្រមូលផល | | |
| ២០០៨ | ២,៥៥២ | ២,៦១៥ | ២,៦១៣ | ២,៧៤៦ | ៧,១៧៥ |
| ២០០៩ | ២,៥៥២ | ២,៧១៩ | ២,៦៧៥ | ២,៨៣៦ | ៧,៥៨៦ |
| ២០១០ | ២,៦១៧ | ២,៧៩៦ | ២,៧៧៦ | ២,៩៧ | ៨,២៤៩ |
| ២០១១ | ២,៦៨៨ | ២,៩៦០ | ២,៧៦០ | ៣,១៧០ | ៨,៧៧៩ |
| ២០១២ | ២,៧៣៦ | ២,៩៩៨ | ២,៩៧០ | ៣,១៣២ | ៩,៣០៥ |

- ក្នុងឆ្នាំ២០១២នេះ ផ្ទៃដីប្រមូលផលមាន ២,៩៧០លានហិកតា (ស្រូវវស្សាៈ ២,៤៨៦លានហ.ត និងស្រូវរដូវប្រាំងៈ ៤៨៤ ៥៦៩ ហ.ត)។ បរិមាណផលសរុប ៩,៣០៥ លានតោន ក្នុងនោះ ស្រូវរដូវវស្សា ៧,១៥៩ លានតោន និងស្រូវរដូវប្រាំង ២,១៤៥លានតោន។ ស្រូវនៅសល់ជាស្បៀង ៨,០៩៥លានតោន គិតជាអង្ករ ៦៤% ស្មើនឹង ៥,១៨១លានតោន បន្ទាប់ពីកាត់ចេញ សម្រាប់ទុកពូជ ចំណីសត្វ និងបាត់បង់ដោយការប្រមូលផល។ តម្រូវការអង្ករជាស្បៀងសម្រាប់ប្រជាពលរដ្ឋ ១៤ ៩៨០ ២៧០នាក់ ស្មើនឹង ២,១៤២លានតោន។

អតិរេកអង្ករសម្រាប់បម្រើឲ្យគោលដៅនាំចេញ មាន ៣ ០៣៩ ១៣៥តោន គិតជាស្រូវ ៤ ៧៤៨ ៦៤៨តោន។

- បន្ទាប់ពីរាជរដ្ឋាភិបាលបានដាក់ចេញគោលនយោបាយ ស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ដើម្បីឈានទៅសម្រេចគោលដៅនាំចេញអង្ករចំនួន ១លានតោន នៅឆ្នាំ២០១៥។ តាមការប៉ាន់ស្មានការនាំចេញអង្ករ នឹងអាចសម្រេចបានរហូតដល់ ៤០ម៉ឺនតោន នៅឆ្នាំ២០១២នេះ អាស្រ័យដោយការរៀបចំបានល្អ និងការខិតខំពង្រីកបានទីផ្សារអង្ករ។ ការកើនឡើងនៃទីផ្សារអង្ករកម្ពុជាបច្ចុប្បន្ន ដោយសារឥរិយាបថរបស់កសិករកំពុងមានការប្រែប្រួល ពីផលិតកម្មតាមបែបធម្មជាតិ ទៅរកផលិតកម្មតាមបែបប្រពលវប្បកម្ម និងពីការផលិតជាលក្ខណៈគ្រួសារ មកជាការផលិតជាលក្ខណៈទំនិញ។
- កំណើននៃវិស័យកសិកម្ម មានដំណាំស្រូវ កៅស៊ូ ពោត សណ្តែក និងដំឡូងមីជាដើម។

**✡ដំណាំកៅស៊ូនិងការចិញ្ចឹមសត្វ**

| ផលិតកម្មកៅស៊ូ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ |
|---|---|---|---|---|---|
| ផ្ទៃដីដាំកៅស៊ូសរុប (ពាន់ហិកតា) | ១០៧ | ១២៦ | ១៨១,៤ | ២១៣,១ | ២៨០,៤ |
| ផ្ទៃដីចៀរជ័រ (ពាន់ហិកតា) | ១៩,២ | ៣៤,១ | ៣៨,៤ | ៤៥,២ | ៤៥,២ |
| ផលិតផលកៅស៊ូ (ពាន់តោន) | ១៦,៥ | ៣៧,៤ | ៤២,៣ | ៥១,៣ | ៥១,៥៣ |

| ការចញ្ចឹមសត្វ ឯកតា( ពាន់ក្បាល) | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ |
|---|---|---|---|---|---|
| ការចិញ្ចឹមសត្វគោ | ៣ ៤៥៧ | ៣ ៥៧៩ | ៣ ៨៨៤ | ៣ ៤០៦ | ៣ ៣៧៧ |
| ការចិញ្ចឹមសត្វក្របី | ៧៤៦ | ៧៣៩ | ៧០២ | ៦៨៩ | ៦៥៧ |
| ការចិញ្ចឹមសត្វជ្រូក | ២ ២១៦ | ២ ១២៦ | ២ ០៥៧ | ២ ០៩៩ | ២ ២០៩ |
| ការចិញ្ចឹមសត្វស្លាប | ១៦ ៩២៨ | ២០ ១៩២ | ២០ ៨៣៤ | ២២ ០៣៦ | ៣ ៣៤៨ |

## ២-កំណែទម្រង់ដីធ្លី

*នៅឆ្នាំ២០១២នេះ រាជរដ្ឋាភិបាលបានរំសាយឡូត៍នេសាទបន្ថែមចំនួន៨០ឡូត៍ មានផ្ទៃសរុបចំនួន ៤១៥ ២១៨ហិកតាដែលក្នុងនោះ ផ្ទៃឡូត៍ នេសាទប្រមាណ ៣១៧ ៧១៥ហិកតា ស្មើនឹង៧៦,៥០% ទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ និងរៀបចំសហគមន៍*

*នេសាទបន្ថែមថ្មី ចំនួន៤៧សហគមន៍នេសាទ ដើម្បីគ្រប់គ្រងនិងប្រើប្រាស់ធនធានជលផល ប្រកបដោយនិរន្តរភាព។ ក្រៅពីនោះ ផ្ទៃឡូត៍នេសាទប្រមាណ៩៧ ៥០៣ហិកតា ស្មើនឹង២៣,៥០%ត្រូវបានកំណត់ទុកជាតំបន់អភិរក្ស សម្រាប់ការពារថែរក្សាពូជត្រី សំដៅធានាផលស្តុកត្រីសម្រាប់ឆ្នាំក្រោយៗទៀត។*

*ការកែទម្រង់ស៊ីជម្រៅលើវិស័យជលផលទាំងពីរលើកមានផ្ទៃឡូត៍នេសាទសរុបទាំងអស់ចំនួន ៩៥៣ ៧៤០ហិកតា ត្រូវបានលុបសម្រាប់រៀបចំសហគមន៍នេសាទ និងធ្វើកន្លែងអភិរក្សជលផល។ ជាងនេះទៀត រាជរដ្ឋាភិបាលបានចាត់ទុកកំណែទម្រង់ស៊ីជម្រៅនេះជាយុទ្ធសាស្ត្រលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដើម្បីការរីកចម្រើននៃសេដ្ឋកិច្ចសង្គម និងការអភិវឌ្ឍប្រទេសជាតិ។*

## ៣- កំណែទម្រង់ព្រៃឈើ

- *រាជរដ្ឋាភិបាលកម្ពុជា បានផ្តោតការយកចិត្តទុកដាក់លើកម្មវិធីកំណែទម្រង់វិស័យព្រៃឈើ ដោយខិតខំបង្កើនសមត្ថភាពបច្ចេកទេស សំដៅជំរុញការងារគ្រប់គ្រងឱ្យមានប្រសិទ្ធភាពខ្ពស់ រក្សាការពារនិងធានានិរន្តរភាពព្រៃឈើ។ ច្បាប់ស្តីពីព្រៃឈើ គឺជាត្រីវិស័យនិងជាឧបករណ៍ដ៏សំខាន់សម្រាប់ការគ្រប់គ្រងវិស័យព្រៃឈើជាតិ។*
- **ក្នុងឆ្នាំ២០១០ ផ្ទៃដីព្រៃឈើមានទំហំសរុប ១០ ៣៦៣ ៧៨៩ហិកតាស្មើនឹងប្រមាណ ៥៨% នៃផ្ទៃដីសរុបរបស់ប្រទេស។ រាជរដ្ឋាភិបាលមានទិសដៅបង្កើនផ្ទៃដីដែលគ្របដណ្តប់ដោយព្រៃឈើឲ្យដល់៦០% នៅឆ្នាំ២០១៥។**
- *បានបោះបង្គោលព្រំដែនព្រៃបម្រុងទុកជាអចិន្ត្រៃយ៍បានប្រវែងសរុប ២ ០២០គ.ម. ដោយថវិការដ្ឋ អង្គការJICA DANIDA WILDLIFE ALLIANCE និងអង្គការCI។*

### ✡ ការគ្រប់គ្រងបរិស្ថាន

ក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៣ គណៈរដ្ឋមន្ត្រីបានសម្រេចអនុម័តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០ ដែលមានគោលបំណងធ្វើអោយមានការអភិវឌ្ឍបៃតង ដោយធានាបាននូវស្ថិរភាពនយោបាយនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដើម្បីឈានឡើងជាប្រទេសអភិវឌ្ឍន៍ និងមានគោលដៅជំរុញសេដ្ឋកិច្ចជាតិអោយមានកំណើនថេរ កាត់បន្ថយនិងទប់ស្កាត់ការបំពុលបរិស្ថាន រក្សាសុវត្ថិភាពប្រព័ន្ធអេកូឡូស៊ី កាត់បន្ថយភាពក្រីក្រ បង្កើនសេវាសុខភាពសាធារណៈ និងគុណភាពអប់រំ គ្រប់គ្រងធនធានធម្មជាតិ ការប្រើប្រាស់ដីធ្លីនិងធនធានទឹកប្រកបដោយនិរន្តរភាព បង្កើនប្រសិទ្ធភាពថាមពល ធានាសុវត្ថិភាពចំណីអាហារ និងលើកតម្កើងវប្បធម៌ជាតិ។

✡ **ការងារគ្រប់គ្រងគ្រោះមហន្តរាយ**

-គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដោយមានការសហការគាំទ្រពីអង្គការដៃគូកសាងបានផែនការត្រៀមបម្រុងសម្រាប់ឆ្លើយតបគ្រោះមហន្តរាយនៅខេត្តចំនួន១១ ដែលតែងតែជួបប្រទះគ្រោះទឹកជំនន់ដូចជា ខេត្តស្ទឹងត្រែង ក្រចេះ កំពង់ចាម ព្រៃវែង កណ្ដាល ស្វាយរៀង តាកែវ កំពង់ធំ បន្ទាយមានជ័យ កំពង់ឆ្នាំង និងខេត្តពោធិ៍សាត់។ ផែនការនេះត្រូវបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ហើយមានប្រយោជន៍ដល់ការត្រៀមបម្រុងសម្រាប់ឆ្លើយតបគ្រោះមហន្តរាយ។

-បានបង្កើតទីទួលសុវត្ថិភាព ដែលរួមទាំងទីទួលធម្មជាតិ និងទីទួលដែលជាសំណង់បំពាក់ដោយឧបករណ៍ដូចជា បន្ទប់ទឹក បង្គន់អនាម័យ ជម្រកមនុស្ស សត្វ ដោយមានកិច្ចសហការជាមួយអង្គការ CARITAS, OXFAM... រួមមានចំនួន ៩៥៨កន្លែង នៅស្រុកចំនួន១១២ នៃខេត្តចំនួន១៧ ក្នុងនោះមាន ខេត្តក្រចេះ ស្ទឹងត្រែង កំពង់ចាម កណ្ដាល ព្រៃវែង ព្រះវិហារ កំពង់ធំ ស្វាយរៀង បន្ទាយមានជ័យ ពោធិ៍សាត់ កំពត តាកែវ កំពង់ឆ្នាំង ឧត្តរមានជ័យ បាត់ដំបង កំពង់ស្ពឺ និងខេត្តសៀមរាប។

-បានធ្វើការចែកចាយស្បៀង ពូជស្រូវនិងជី ដល់ប្រជាពលរដ្ឋក្រីក្រនៅខេត្តចំនួន៧ នៅជុំវិញបឹងទន្លេសាប ដែលមានប្រជាពលរដ្ឋទទួលផលចំនួន ៣៤២ ៨៥៣គ្រួសារ នៅឃុំគោលដៅចំនួន ២០០។

## ៤-កំណែទម្រង់ដីធ្លី និងការបោសសម្អាតមីន

### ៤.១-កំណែទម្រង់ដីធ្លី

#### ក-ការងារចុះបញ្ជីដីធ្លី

- រាជរដ្ឋាភិបាលបានចេញបទបញ្ជាលេខ ០១បប ស្ដីពីវិធានការពង្រឹងនិងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២ ជាអាទិ៍ ផ្អាកជាបណ្ដោះអាសន្ននូវការផ្ដល់ដីសម្បទានសេដ្ឋកិច្ច និងការដាក់ចេញនូវវិធានការមួយចំនួន ដើម្បីផ្ដល់ផលប្រយោជន៍ពិតប្រាកដ ជូនដល់ប្រទេសជាតិ និងប្រជាជនប្រកបដោយចីរភាព។
- បានអនុវត្តបទបញ្ជាលេខ០១បប (នយោបាយចាស់ សកម្មភាពថ្មីលើវិស័យដីធ្លី)៖ ចុះបញ្ជីបណ្ណកម្មសិទ្ធិចំនួន ១៤៨ ៥៥២បណ្ណ។
- ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ៖ ចុះបញ្ជីបណ្ណកម្មសិទ្ធិបានចំនួន ២ ២៥៧ ១៥១បណ្ណ។
- ការចុះបញ្ជីដីសម្បទានសេដ្ឋកិច្ច៖ អនុវត្តបាន ១៣០បណ្ណ ស្មើនឹង ១០១ ១៧៩ហិកតា។

## ខ-ការបែងចែកដីក្នុងគោលដៅសម្បទានដីសង្គមកិច្ចនិងប្រទានកម្ម

- សម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ សម្រេចបានប្រមាណជាង ៤ ០០០គ្រួសារ។
- សម្បទានដីសង្គមកិច្ចជូនយោធិន និងគ្រួសារ ដែលកំពុងឈរជើងការពារតំបន់ព្រំដែនទិសខាងលិចនិងខាងជើង សម្រេចបានប្រមាណ ៧ ០០០គ្រួសារ។
- សម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រស៊ីវិលទូទៅតាមគ្រប់រូបភាព (ប្រទានកម្ម និយ័តកម្ម) សម្រេចបានប្រមាណ ១៥ ០០០គ្រួសារ។
- គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដោយសហការជាមួយដៃគូអភិវឌ្ឍ និងអង្គការជាតិ អន្តរជាតិ សម្រេចបានប្រមាណជិត ៥ ០០០គ្រួសារ។

## គ-ការគ្រប់គ្រងនិងការអភិវឌ្ឍវិស័យសំណង់

| បរិយាយ | ចំនួនគម្រោង | ផ្ទៃក្រឡាសំណង់ (ម$^{២}$) | តម្លៃប៉ាន់ស្មាន (ដុល្លារអាមេរិក) | ប្រៀបធៀប(%) |
|---|---|---|---|---|
| ២០០៨ | ២ ១៥៦ | ១០ ៣៣៩ ៦៤២ | ៣ ១៩១ ៥៦៩ ១៤៤ | |
| ២០០៩ | ២ ២៣០ | ៦ ៦១៤ ៧៤៧ | ១ ៩៨៨ ៨៥១ ៩៥១ | |
| ២០១០ | ២ ១៤៩ | ៣ ២៨៧ ៤៦៨ | ៨៤០ ៤៥៩ ៥២៩ | |
| ២០១១ | ២ ១២៩ | ៥ ២៥៧ ៥៨៧ | ១ ៧៣៤ ៥៩៨ ៥៨៤ | +១០៦,៣៨% ធៀបនឹងឆ្នាំ ២០១០ |
| ២០១២ | ១ ៦៩៤ | ៦ ៥២៨ ៤៥២ | ២ ១០៩ ៦០៧ ២៤២ | +៧១,៩៧%ធៀបនឹងឆ្នាំ២០១១ |

- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានធ្វើវិមជ្ឈការមុខងារឲ្យទៅសាលាក្រុង ស្រុក ខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតសាងសង់ និងសេវាកម្មពាក់ព័ន្ធនឹងការសាងសង់សំណង់ ដែលមានទំហំតូចជាងឬស្មើ ៥០០ម$^{២}$ នៅការិយាល័យច្រកចេញ ចូលតែមួយនៃក្រុង ស្រុក ខណ្ឌគោលដៅចំនួន ២៣។
- គិតត្រឹមឆ្នាំ២០១២ សហគ្រាសនិងក្រុមហ៊ុនសាងសង់ និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ក្នុងស្រុក និងបរទេស បានមកចុះបញ្ជីចំនួន ១ ២០៥ ក្រុមហ៊ុន។

### ៤.២-ការបោសសម្អាតមីន

● អត្រាគ្រោះថ្នាក់ដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមបានធ្លាក់ចុះយ៉ាងខ្លាំងពីចំនួនជាង២០០ករណី ពីឆ្នាំ២០០៨ដល់ឆ្នាំ២០១១ ហើយបានធ្លាក់ចុះជាបន្តបន្ទាប់មកត្រឹម ១៨៦ករណីនៅក្នុងឆ្នាំ ២០១២។

● គិតចាប់ពីឆ្នាំ២០០៨រហូតដល់ឆ្នាំ២០១២ សកម្មភាពបោសសំអាតមីនដោយប្រតិបត្តិករ ស៊ីម៉ាក់ កងយោធពលខេមរភូមិន្ទ អង្គការហាឡូត្រាស់ និងអង្គការម៉ែក ដែលមានកម្លាំងសរុបប្រមាណជាង ៥ ០០០នាក់ បានរំដោះផ្ទៃដីដែលមាន ឬសង្ស័យថាមានមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម សម្រាប់សាងសង់លំនៅឋាន ភូមិករ សាលារៀន មណ្ឌលសុខភាព ផ្លូវថ្នល់ ដីកសិកម្ម សម្រេចបានផ្ទៃដីសរុបប្រមាណជាង ៥៣១គ.ម.² រកឃើញមីនប្រឆាំងមនុស្សចំនួន ២១៤ ៧៩៩គ្រាប់ មីនប្រឆាំងរថក្រោះចំនួន ៤ ៣០២គ្រាប់ សំណល់ជាតិផ្ទុះពីសង្គ្រាមចំនួន៧១១ ៥៧០គ្រាប់ អំបែងគ្រាប់ចំនួន ៦៧ ៣៣១ ៣២៩អំបែង ។

## II-ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

### ១-ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍

| បរិយាយ | ឯកតា | ២០០៩ | ២០១០ | ២០១១ | ២០១២ |
|---|---|---|---|---|---|
| ប្រវែងផ្លូវក្រាលកៅស៊ូ (ផ្លូវជាតិ១ខ្ទង់ និង២ខ្ទង់ និងផ្លូវខេត្ត) | គ.ម. | ៣ ២០៤ | ៣ ៤៥៤ | ៣ ៩៥៤ | ៤ ៩៦៩ |
| ការស្តារផ្លូវលំជនបទ | គ.ម. | ២៤ ៥៥៨ | ២៤ ៨៦២ | ក្រាលក្រួសក្រហម ១៨ខ្សែ ប្រវែង ២០៩,៩០៤ | ក្រាលក្រួសក្រហម ៨៩ខ្សែប្រវែង ៦៦៨,០៨៣ ក្រាលបេតុង០២ខ្សែ ៤,៨០០ |
| ផ្លូវលំជនបទក្រាលកៅស៊ូ DBST | ម | ៧ ៩១៣ | ១១ ៨០០ | ៥ខ្សែ ១៨ ៣៧០ | ០២ខ្សែ: ២៩ ៤២៥ |

● ផ្លូវជាតិនិងផ្លូវខេត្ត ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន មកទល់នឹងដំណាច់ឆ្នាំ២០១២ នេះ ៖

១- ផ្លូវជាតិ: ប្រវែងសរុប ៥ ៦០០គ.ម. (ចាក់ក្រាលកៅស៊ូបាន ៣៩៨៣ គ.ម. ស្មើនឹង៧១% នៃប្រវែងសរុប) ក្នុងនោះ ផ្លូវជាតិ១ខ្ទង់ មាន០៩ខ្សែ ប្រវែង ២ ២៥៧ គ.ម. និងផ្លូវជាតិ ២ខ្ទង់ មាន៤៥ខ្សែ ប្រវែង ៣ ៣៤៣ គ.ម. ។

២- ផ្លូវខេត្ត: លេខ៣ខ្ទង់ និង៤ខ្ទង់ មាន២៨០ខ្សែ ប្រវែងសរុប ៦ ៦០៧ គ.ម. ក្រាលកៅស៊ូ ប្រវែង ៩៨៦ គ.ម.។

៣- គិតត្រឹមដំណាច់ឆ្នាំ ២០១២ ផ្លូវជាតិ និងផ្លូវខេត្ត មានប្រវែងសរុប ១២ ២០៧ គ.ម. ក្រាលកៅស៊ូរួច ប្រវែង ៤៩៦៩ គ.ម. ស្មើនឹង ៤១% នៃប្រវែងផ្លូវសរុប។

- ដោយឡែក ផ្លូវក្រួសក្រហមនៅជនបទ កំពុងប្រែក្លាយទៅជាផ្លូវក្រាលកៅស៊ូឬផ្លូវបេតុងជាជំហានៗ។

## ✡ ស្ពាននិងផ្លូវដែកដែលបាននិងកំពុងស្ថាបនា គិតមកដល់ដំណាច់ឆ្នាំ២០១២

១- ស្ពានអ្នកលឿង ឆ្លងកាត់ទន្លេមេគង្គក្រោម ពីខាងលិចខេត្តកណ្តាល ទៅខាងកើតខេត្តព្រៃវែង តភ្ជាប់ផ្លូវជាតិលេខ១ មានបណ្តោយ ២ ២២០ម ទទឹង ១៤ម សម្រេចបាន ៤៩,៨០%។

២-ស្ពានមិត្តភាពកម្ពុជា-ចិន (ស្ពានស្ទឹងត្រែង ឆ្លងកាត់ទន្លេមេគង្គលើ) តភ្ជាប់ផ្លូវជាតិលេខ៩ ខេត្តស្ទឹងត្រែង មានបណ្តោយ ១៧៣១ម ទទឹង ១៣,៥០ម សម្រេចបាន ៣៦,២៦%។

៣-ស្ពានមិត្តភាពកម្ពុជា-ចិន (ស្ពានតាខ្មៅ) ក្រុងតាខ្មៅ ខេត្តកណ្តាល ឆ្លងកាត់ទន្លេបាសាក់ មានបណ្តោយ ៧៩៥ម ទទឹង ១៣,៥០ម សម្រេចបាន ៤១,៣២%។

៤-ស្ពានមិត្តភាព កម្ពុជា-ចិន (ស្ពានជ្រោយចង្វារទី២) រាជធានីភ្នំពេញ ឆ្លងកាត់ទន្លេសាប មានបណ្តោយ ៧១៩ម ទទឹង ១៣,៥០ម សម្រេចបាន ៤០,៦៨%។

៥-ផ្លូវដែកខ្សែទី១ ពីរាជធានីភ្នំពេញដល់ខេត្តព្រះសីហនុ មានប្រវែង ២៦៦គ.ម. សម្រេចបាន ៩៣,៧០% និងខ្សែទី២ ពីរាជធានីភ្នំពេញដល់ប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ព្រំដែនកម្ពុជា-ថៃ ប្រវែង ៣៨៦គ.ម. សម្រេចបាន ៣២%។

## ✡ការដឹកជញ្ជូននៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ

| បរិយាយ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ |
|---|---|---|---|---|---|
| ទំនិញឆ្លងកាត់ផែ (តោន) | ២ ០៥៧ ៩៦៧ | ១ ៨៧៤ ០៩៥ | ២ ២១៧ ១៥០ | ២ ៤៣៩ ៣៨៤ | ២ ៦៥៩ ៧៨៥ |
| នាវាចូលចត (គ្រឿង) | ៩៥៤ | ៨៤៧ | ៩០៥ | ៨៧៧ | ៩៤១ |
| កុងតៃន័រឆ្លងកាត់ (TEU) | ២៥៨ ៧៧៥ | ២០៧ ៨៦១ | ២២២ ៩២៨ | ២៣៧ ៩៤១ | ២៥៥ ៣៧៨ |
| ភ្ញៀវទេសចរ (នាក់) | ១១ ៧៨៨ | ១៩ ៨៥៣ | ២៤ ១៤២ | ៧ ៩៦៤ | ២០ ២៩៨ |
| ចំណូលអាជីវកម្ម (ដុល្លារ) | ៣០ ៣០២ ៣៥៧ | ២៥ ១៥៤ ៨៨១ | ២៨ ៤០២ ៣៨០ | ៣១ ០៩០ ៤៨០ | ៣៥ ៤៥៧ ៧០៦ |

## ✡ការដឹកជញ្ជូននៅកំពង់ផែស្វយ័តភ្នំពេញ

| បរិយាយ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ |
|---|---|---|---|---|---|
| ទំនិញឆ្លងកាត់ផែ (តោន) | ១ ២៤០ ៣៣៩ | ១ ១៩៨ ២១៨ | ១ ២៤៧ ៤២៤ | ១ ៤១៥ ៤២៦ | ១ ៦៣២ ៨១០ |
| នាវាចូលចត (គ្រឿង) | ១ ៥៤៣ | ១ ៥២០ | ១ ៤៣៥ | ១ ៥៨៣ | ១ ៦៣០ |
| កុងតែន័រឆ្លងកាត់ (TEU) | ៤៧ ៥០៧ | ៤៣ ៣១២ | ៦២ ២៥៦ | ៨១ ៦៣១ | ៩៥ ៣៣៣ |
| នាវាអ្នកដំណើរ (គ្រឿង) | ៥៥១ | ៧៣៥ | ១ ៩៥៦ | ២ ១៧៣ | ២ ៨៥១ |
| អ្នកដំណើរឆ្លងកាត់ | ២៩ ០២៤ | ២០ ៨៨៥ | ២៣ ៧៥៨ | ១៧ ៨៨៥ | ៥៧ ២៩១ |
| ចំណូលអាជីវកម្ម (ដុល្លារ) | ៥ ២៧៨ ៤៤១ | ៥ ១៨៣ ៥៦៦ | ៦ ៥៩០ ៦០៤ | ៨ ២៦៩ ៦៥៣ | ៨ ៧៣៥ ៨៨៣ |

## ✡ ការដឹកជញ្ជូនតាមផ្លូវអាកាស

| បរិយាយ | ២០០៩ | ២០១០ | ២០១១ | ២០១២ |
|---|---|---|---|---|
| ហោះហើរចុះចតក្នុងស្រុក(ជើង) | ៥ ៨៥៦ | ៤ ៩០៩ | ៤ ៨៩៧ | ៥ ៥០៦ |
| ហោះហើរអន្តរជាតិ(ជើង) | ១៤ ៨៧២ | ១៦ ២៦២ | ១៨ ៤៣៨ | ២០ ១៣១ |
| ហោះហើរឆ្លងកាត់ (ជើង) | ២៦ ២៣៥ | ២៩ ៨២៣ | ៣៤ ៧២៤ | ៣៤ ៦៨៧ |
| ដឹកភ្ញៀវក្នុងប្រទេស (នាក់) | ១៤៣ ៦៤៩ | ១៣៥ ៥២២ | ១៤៤ ១០៥ | ១៧៨ ៦៥៥ |
| ដឹកភ្ញៀវក្រៅប្រទេស (នាក់) | ២ ៦០១ ៥៩១ | ៣ ០៦១ ៨៣១ | ៣ ៤៦៤ ៥៧៨ | ៣ ៩៩៦ ៨០៣ |
| ដឹកអីវ៉ាន់ក្នុងប្រទេស (គ.ក្រ.) | ១ ៤២៧ ០៨២ | ១ ២៩៥ ៦៥១ | ១ ២៨១ ៣១១ | ១ ៤៩៤ ០៤១ |
| ដឹកអីវ៉ាន់ក្រៅប្រទេស (គ.ក្រ.) | ៣៦ ១៩៣ ១៣៤ | ៤០ ៩៩៥ ៦១៨ | ៤៦ ៧០៦ ១៦៥ | ៤៩ ០៤៤ ៦១៣ |
| ដឹកទំនិញក្នុងប្រទេស (គ.ក្រ.) | ៧ ៥២៥ | ២១ | ១២ ៣៤០ | ៥០៨ |

| | | | | |
|---|---|---|---|---|
| ដឹកទំនិញក្រៅប្រទេស (គ.ក្រ.) | ១៥ ៣៥៩ ៤៥០ | ១៧ ៧៦៨ ៤៥៦ | ២០ ០៧៤ ២២២ | ២៧ ៨១១ ៣៨៥ |
| ដឹកកញ្ចប់ប្រៃសណីយ៍ក្រៅប្រទេស(គ.ក្រ) | ៣៧៤ ៦៣៤ | ៤០៤ ០៩០ | ៦៤៣ ៨៣៣ | ៦៧៨ ៦៧៧ |
| ចំណូលបង់ចូលថវិការដ្ឋ (ដុល្លារអាមេរិក) | ១៣ ៥៩៩ ៦៩៣ | ១៣ ៥២៩ ៤៣៨ | ១៥ ៥៦៤ ៦៥៦ | ១៦ ២៤៧ ០៨០ |

- ឆ្នាំ២០១២ ការដឹកជញ្ជូនភ្ញៀវក្នុង និងក្រៅប្រទេសបាន ៤ ១៧៥ ៤៥៨នាក់ កើនឡើង ៣៧,១៧% បើធៀបនឹងឆ្នាំ២០០៨ ដឹកជញ្ជូនអីវ៉ាន់តាមផ្លូវអាកាសទាំងក្នុងប្រទេស និងក្រៅប្រទេសបានចំនួន ៥០ ៥៣៨ ៦៥៤ គ.ក្រ. កើនឡើង២១,៣១%បើធៀបនឹងឆ្នាំ២០០៨ ដឹកជញ្ជូនទំនិញបានចំនួន ២៧ ៨១១ ៨៩៣គ.ក្រ. កើនឡើង ២៦,៤៣% បើធៀបនឹងឆ្នាំ២០០៨ កញ្ចប់ប្រៃសណីយបានចំនួន ៦៧៨ ៦៧៧គ.ក្រ. កើនឡើង ៧,២៥% បើធៀបនឹងឆ្នាំ២០០៨ ។ ចំណូលបង់ចូលថវិការដ្ឋបាន ១៦ ២៤៧ ០៨០ដុល្លារអាមេរិក កើនឡើង ៣៥,៣៦% បើធៀបនឹងឆ្នាំ២០០៨។
- ដោយឡែកឆ្នាំ២០១៣ តាមការវាយតម្លៃ នឹងមានកំណើនកើនលើការងារដឹកជញ្ជូនពី ០៨ ទៅ១០% ដោយសារកំណើននៃក្រុមហ៊ុនដឹកជញ្ជូនផ្លូវអាកាស។

### ☞ក្រុមហ៊ុនអាកាសចរណ៍ជាតិ និងអន្តរជាតិ ដែលមាន ច្បាប់អនុញ្ញាតហោះហើរចេញ ចូលព្រះរាជាណាចក្រកម្ពុជា

| ល.រ. | ឈ្មោះក្រុមហ៊ុន | ថ្ងៃ ខែ ឆ្នាំ អនុញ្ញាតឲ្យហោះហើរ |
|---|---|---|
| ១ | ក្រុមហ៊ុនអាកាសចរណ៍ Vietnam Airlines | ០១ កញ្ញា ១៩៧៩ |
| ២ | ក្រុមហ៊ុនអាកាសចរណ៍ Lao Airlines | ០១ មករា ១៩៨២ |
| ៣ | ក្រុមហ៊ុនអាកាសចរណ៍ Bangkok Airways | ២៥ តុលា ១៩៩០ |
| ៤ | ក្រុមហ៊ុនអាកាសចរណ៍ Malaysia Airlines | ១៧ មីនា ១៩៩២ |
| ៥ | ក្រុមហ៊ុនអាកាសចរណ៍ Thai Airways | ០១ តុលា ១៩៩២ |
| ៦ | ក្រុមហ៊ុនអាកាសចរណ៍ Silk Air | ០១ តុលា ១៩៩២ |
| ៧ | ក្រុមហ៊ុនអាកាសចរណ៍ Dragon Air | ០១ កុម្ភៈ ១៩៩៣ |
| ៨ | ក្រុមហ៊ុនអាកាសចរណ៍ China Southern Airlines | ០១ កុម្ភៈ ១៩៩៩ |
| ៩ | ក្រុមហ៊ុនអាកាសចរណ៍ Eva Airways | ០១ មករា ២០០២ |
| ១០ | ក្រុមហ៊ុនអាកាសចរណ៍ China Eastern | ០១ មករា ២០០៤ |

| | | |
|---|---|---|
| ១១ | ក្រុមហ៊ុនអាកាសចរណ៍ Asiana Airlines | ០១ មេសា ២០០៥ |
| ១២ | ក្រុមហ៊ុនអាកាសចរណ៍ Thai Air Asia | ៣០ តុលា ២០០៥ |
| ១៣ | ក្រុមហ៊ុនអាកាសចរណ៍ Air Asia Berhad | ០១ វិច្ឆិកា ២០០៥ |
| ១៤ | ក្រុមហ៊ុនអាកាសចរណ៍ Korean Air | ០១ វិច្ឆិកា ២០០៦ |
| ១៥ | ក្រុមហ៊ុនអាកាសចរណ៍ China Airlines | ០១ វិច្ឆិកា ២០០៦ |
| ១៦ | ក្រុមហ៊ុនអាកាសចរណ៍ Jetstar Airways | ០១ ធ្នូ ២០០៨ |
| ១៧ | ក្រុមហ៊ុនអាកាសចរណ៍ Cambodia Angkor Air | ២៧ កក្កដា ២០០៩ |
| ១៨ | ក្រុមហ៊ុនអាកាសចរណ៍ Tonel Sap Airlines | ២១ មករា ២០១១ |
| ១៩ | ក្រុមហ៊ុនអាកាសចរណ៍ Skywing Asia Airlines | ១៣ កុម្ភៈ ២០១១ |
| ២០ | ក្រុមហ៊ុនអាកាសចរណ៍ Myanmar Airways | ០១ មីនា ២០១១ |
| ២១ | ក្រុមហ៊ុនអាកាសចរណ៍ Air France | ២៨ មីនា ២០១១ |
| ២២ | ក្រុមហ៊ុនអាកាសចរណ៍ Cebu Pacific | ២៧ មីនា ២០១២ |
| ២៣ | ក្រុមហ៊ុនអាកាសចរណ៍ Tiger Airways | ០១ តុលា ២០១២ |
| ២៤ | ក្រុមហ៊ុនអាកាសចរណ៍ Condor Air | ០៣ វិច្ឆិកា ២០១២ |

## ២-ការអភិវឌ្ឍវិស័យថាមពល

| បរិយាយ | ការផលិតថាមពលអគ្គិសនីរបស់អគ្គិសនីកម្ពុជា (លានKwh) | ការផលិតថាមពលអគ្គិសនីក្រោមការគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (លានKwh) | ការនាំចូលថាមពលពី (លានKwh) | | |
|---|---|---|---|---|---|
| | | | សាធារណរដ្ឋសង្គមនិយមវៀតណាម | ព្រះរាជាណាចក្រថៃឡង់ដ៍ | សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ |
| ២០០៩ | ១ ០៩៨,៧ | ១៣,៧ | ៥០០,៧ | ២២៦,៧ | ០ |
| ២០១០ | ៨៤៦,៤ | ២៤,៣ | ១ ០៧២,៨ | ២៧០,២ | ៥,២ |
| ២០១១ | ៩៣៩,៣ | ២៨,១ | ១ ២៨០,១ | ៣៩២,៣ | ៦,៣ |
| ២០១២ | ១ ៨០៩,៩ | ៣១,៦ | ១ ៤១៥,៣ | ៤៤៧,៦ | ៨,៦ |

♦នៅជាប់ព្រំដែនកម្ពុជា-វៀតណាម រាជរដ្ឋាភិបាលបាន នាំចូលថាមពលអគ្គិសនីមកប្រើប្រាស់តាមបណ្តោយព្រំដែនមួយចំនួន ហើយនៅភ្នំដិន ខេត្តតាកែវ បាននាំចូលមកប្រើដល់រាជធានីភ្នំពេញ។

- នៅព្រំដែនកម្ពុជា-ថៃ រាជរដ្ឋាភិបាល បាននាំចូលថាមពលអគ្គិសនីមកប្រើប្រាស់តាមបណ្តោយព្រំដែនមួយចំនួន ហើយនៅប៉ោយប៉ែតបាននាំចូលមកប្រើប្រាស់ដល់ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ក្រុងបាត់ដំបង និងក្រុងសៀមរាប។
- នៅព្រំដែនកម្ពុជា-ឡាវ រាជរដ្ឋាភិបាលបាននាំចូលថាមពលអគ្គិសនីមកប្រើប្រាស់ដល់ក្រុងស្ទឹងត្រែង។
- ការផ្គត់ផ្គង់ថាមពលអគ្គិសនីដល់ជនបទ បានកើនដល់ជិត ៥០% នៃចំនួនភូមិទូទាំងប្រទេស។

## ☆ការងារសាងសង់វារីអគ្គិសនី

១-គម្រោងវារីអគ្គិសនីស្ទឹងអាតៃ មានអានុភាព១២០មេហ្គាវ៉ាត់ នៅឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិសាត់ កំពុងបន្តដំណើរការសាងសង់បានប្រមាណ៩០% និងគ្រោងបញ្ចប់ការសាងសង់នៅឆ្នាំ២០១៣។

២-គម្រោងវារីអគ្គិសនីស្ទឹងឫស្សីជ្រុំក្រោម មានអានុភាព៣៣៨មេហ្គាវ៉ាត់ នៅឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង កំពុងបន្តដំណើរការសាងសង់បានប្រមាណ៧០% និងគ្រោងដំណើរការនៅដើមឆ្នាំ២០១៤។

៣-គម្រោងវារីអគ្គិសនីស្ទឹងតាតៃ មានអានុភាព ២៤៦មេហ្គាវ៉ាត់ នៅឃុំឫស្សីជ្រុំ ស្រុកថ្មបាំង និងឃុំតាតៃ ស្រុកកោះកុង ខេត្តកោះកុង កំពុងបន្តដំណើរការសាងសង់បានប្រមាណ ៧០% និងគ្រោងដំណើរការនៅចុងឆ្នាំ ២០១៥។

## ☆ការសាងសង់រោងចក្រផលិតថាមពលអគ្គិសនីដុតធ្យូងថ្ម

១-គម្រោងសាងសង់រោងចក្រអគ្គិសនីដុតធ្យូងថ្ម នៅខេត្តព្រះសីហនុ របស់ក្រុមហ៊ុន Cambodian Energy បានសិទ្ធិសម្បទានសម្រាប់គម្រោង១០០មេហ្គាវ៉ាត់ សាងសង់សម្រេចបាន៨២% និងគ្រោងដំណើរការក្នុងខែឧសភា ឆ្នាំ២០១៣។

២-គម្រោងសាងសង់រោងចក្រអគ្គិសនីដុតធ្យូងថ្ម អានុភាព២៧០មេហ្គាវ៉ាត់ ជំហានទី១ នៃផែនការអភិវឌ្ឍន៍រោងចក្រអគ្គិសនីដើរដោយធ្យូងថ្ម ៧០០មេហ្គាវ៉ាត់ នៅខេត្តព្រះសីហនុ របស់ក្រុមហ៊ុន CambodiaInternational Investment Development Group (CIIDG) សាងសង់បានប្រមាណ១៥% និងគ្រោងដំណើរការនៅឆ្នាំ២០១៤។

## ៣-ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ

### ✡ផ្ទៃដីដែលទទួលបានការស្រោចស្រព

| ឆ្នាំ | លទ្ធភាពស្រោចស្រពដំណាំស្រូវ(ហិកតា) | | |
|---|---|---|---|
| | ស្រូវវស្សា | ស្រូវប្រាំង | សរុប |
| ២០០៩ | ៧៧៣ ១៨៨ | ៣៤៧ ០៥៨ | ១ ១២០ ២៤៦ |
| ២០១០ | ៨០៦ ៤០៤ | ៣៤៧ ០៥៨ | ១ ១៥៣ ៤៦២ |
| ២០១១ | ៩១៦ ០០៥ | ៣៧៩ ៥២១ | ១ ២៩៥ ៥២៦ |
| ២០១២ | ១ ០១០ ២៦៦ | ៤១២ ៥៧៨ | ១ ៤២២ ៨៤៤ |

- ជារួម គិតមកដល់ឆ្នាំ២០១២នេះ ក្នុងក្របខណ្ឌទូទាំងប្រទេស មានលទ្ធភាពស្រោចស្រពលើដំណាំស្រូវសរុបចំនួន ១ ៤២២ ៨៤៤ហិកតា(ស្រូវវស្សា ១០១០ ២៦៦ហិកតា និងស្រូវប្រាំងៈ ៤១២ ៥៧៨ ហិកតា)។
- បើធៀបនឹងផ្ទៃដីបង្កបង្កើនផលស្រូវឆ្នាំ២០១២ ដែលមាន ២ ៧៤០ ៨២២ហិកតា គឺស្មើនឹង ៥១,៩១%។
- រាជរដ្ឋាភិបាលបានចងក្រងសហគមន៍កសិករប្រើប្រាស់ទឹក ពីឆ្នាំ២០០៨ដល់ឆ្នាំ២០១២ បានចំនួន១១១សហគមន៍។បើគិតចាប់ពីឆ្នាំ១៩៩៩ ដល់ឆ្នាំ២០១២ មាន ៤២៨ សហគមន៍។
- លទ្ធភាពការពារទប់ស្កាត់ទឹកជំនន់ពីឆ្នាំ២០០៨ដល់ឆ្នាំ២០១២ អនុវត្តបានលើផ្ទៃដីសរុបចំនួន ៣ ១៧២ហិកតា។ បើគិតចាប់ពីឆ្នាំ១៩៩៩ មកដល់ឆ្នាំ២០១២ អនុវត្តបាន ១៣៦ ៧០៥ហិកតា។
- លទ្ធភាពការពារទប់ស្កាត់ទឹកប្រៃពីឆ្នាំ២០០៨ដល់ឆ្នាំ២០១២ អនុវត្តបានលើផ្ទៃដីសរុបចំនួន ១ ៧២២ហិកតា។ បើគិតចាប់ពីឆ្នាំ១៩៩៩ ដល់ឆ្នាំ២០១២ អនុវត្តបាន ១៩ ២៥៧ហិកតា។

## ៤-ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានគមនាគមន៍

- គិតមកដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២នេះ អត្រាអ្នកប្រើប្រាស់ទូរស័ព្ទចល័តនិងអចល័ត នៅទូទាំងប្រទេស ឡើងដល់ ១៣៣,៥៦ ក្នុងចំណោមប្រជាពលរដ្ឋ១០០នាក់ ស្មើនឹង ១៩ ៦៨៩ ៥៩០គ្រឿង ក្នុងនោះ ទូរស័ព្ទចល័ត ១៩ ១០៥ ១១៥ គ្រឿង មានអត្រាស្មើនឹង ១២៩,៦០ ក្នុងចំណោមប្រជាពលរដ្ឋ ១០០នាក់ និងទូរស័ព្ទអចល័ត ៥៨៤ ៤៧៥គ្រឿងមានអត្រាស្មើនឹង ៣,៩៦ ក្នុងចំណោមប្រជាពលរដ្ឋ ១០០នាក់។
- គិតមកដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២នេះ ចំនួនប្រតិបត្តិករទូរគមនាគមន៍កំពុងធ្វើអាជីវកម្មទូរស័ព្ទចល័តមាន០៨ ទូរស័ព្ទអចល័តមាន០៧ អ៊ិនធើណែតមាន២៧ 3G មាន០៥ មាត់ច្រកអន្តរជាតិមាន០៣ VoIP មាន២៧ និងVSATមាន០១។

♦ ការអភិវឌ្ឍទូរគមនាគមន៍ជនបទ ដោយប្រើប្រាស់ប្រាក់កម្ចី និងការវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធកាប្លិ៍អុបទិក មានប្រវែងសរុប ២២ ៣៨០ គ.ម. គិតជាទឹកប្រាក់វិនិយោគមានប្រមាណ១ ៧០០លានដុល្លារអាមេរិក ក្នុងនោះ ទី១ ក្រុមហ៊ុនទូរគមនាគមន៍កម្ពុជា ប្រវែង ១ ២០០គ.ម. ទី២ ក្រុមហ៊ុន CFOC ប្រវែង ៥ ១៨០គ.ម. និងទី៣ ក្រុមហ៊ុន VIETTEL ប្រវែង ១៦ ០០០គ.ម.។ រចនាសម្ព័ន្ធឆ្អឹងខ្នងរបស់ក្រុមហ៊ុនទាំង៣នេះ ត្រូវបានតភ្ជាប់ទៅសាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងព្រះរាជាណាចក្រថៃឡង់ដ៍។

### ក-ស្ថានីយទូរទស្សន៍

| ឆ្នាំ | ២០០៩ | | ២០១០ | | ២០១១ | | ២០១២ | |
|---|---|---|---|---|---|---|---|---|
| ទីកន្លែង | ភ្នំពេញ | ខេត្ត | ភ្នំពេញ | ខេត្ត | ភ្នំពេញ | ខេត្ត | ភ្នំពេញ | ខេត្ត |
| ស្ថានីយទូរទស្សន៍ | ៩ | ៧ | ១២ | ៤៦ | ១២ | ៤៦ | ១៦ | ៨៨ |
| ស្ថានីយទូរទស្សន៍ខ្សែកាប | ៣ | ១០២ | ២ | ១២៤ | ២១ | ១២៩ | ២ | ១២៥ |

### ខ- ស្ថានីយវិទ្យុ

| ២០០៩ | | ២០១០ | | ២០១១ | | ២០១២ | |
|---|---|---|---|---|---|---|---|
| ភ្នំពេញ | ខេត្ត | ភ្នំពេញ | ខេត្ត | ភ្នំពេញ | ខេត្ត | ភ្នំពេញ | ខេត្ត |
| ៣១ | ៣៨ | ៣៧ | ៥៣ | ៥០ | ៦០ | ៤៣ | ៩៦ |

### គ-សារព័ត៌មានបោះពុម្ព

| ឆ្នាំ | ២០០៩ | ២០១០ | ២០១១ | ២០១២ |
|---|---|---|---|---|
| **កាសែត ព្រឹត្តិបត្រ ទស្សនាវដ្ដី** | ៦៦៩ | ៦៩៥ | ៦៨០ | ៧២១ |

## III-ការអភិវឌ្ឍវិស័យឯកជននិងការងារ

### ១-ការពង្រឹងវិស័យឯកជននិងការទាក់ទាញវិនិយោគ

♦ចាប់ពីឆ្នាំ២០០៨ដល់ឆ្នាំ២០១២ លំហូរទុនវិនិយោគផ្ទាល់ពីបរទេស មានចំនួន ៣ ៥១៨លានដុល្លារអាមេរិក ពោលគឺជាងប្រមាណ ៧០០លានដុល្លារអាមេរិកក្នុងមួយឆ្នាំ។ ការវិនិយោគមានសក្តានុពលបង្កើតការងារថ្មីជាមធ្យមប្រមាណ ១៥០ ០០០ នាក់ ក្នុងមួយឆ្នាំ។ គណៈកម្មាធិការវិនិយោគកម្ពុជា បានសម្រេចអនុញ្ញាតឲ្យក្រុមហ៊ុនធ្វើការវិនិយោគលើគម្រោងថ្មី និងពង្រីក

ផលិតកម្មលើគម្រោងដែលមានស្រាប់ចាប់ពីឆ្នាំ២០០៨ រហូតមកដល់ឆមាសទី១ ឆ្នាំ២០១២ សរុបចំនួន ៥៨៤គម្រោង ដែលមានដើមទុនចុះបញ្ជីប្រមាណ ១ ៣២១លានដុល្លារអាមេរិក និងទុនវិនិយោគប្រមាណ ២៨ ៥២៧លានដុល្លារអាមេរិក ដែលក្នុងនោះវិស័យកសិកម្ម និងកសិឧស្សាហកម្ម ចំនួន១០១គម្រោង វិស័យឧស្សាហកម្ម និងកម្មន្តសាល ចំនួន ៣៧៨ គម្រោង វិស័យទេសចរណ៍ចំនួន ៥៤គម្រោង និងវិស័យហេដ្ឋារចនាសម្ព័ន្ធនិងវិស័យផ្សេងៗទៀត ចំនួន ៥១គម្រោង។

- រាជរដ្ឋាភិបាលបានឯកភាពឲ្យមានការបង្កើតតំបន់សេដ្ឋកិច្ចពិសេសចំនួន ២៥ ។ នៅតាមតំបន់សេដ្ឋកិច្ចពិសេសចំនួន០៨ ដែលបានដំណើរការ មានរោងចក្រចំនួន៧៩ កំពុងមានសកម្មភាពផលិតដោយប្រើប្រាស់កម្លាំងពលកម្មចំនួន ២៩ ៦០០នាក់។ នៅក្នុងបណ្ដាតំបន់សេដ្ឋកិច្ចពិសេសដែលកំពុងដំណើរការនេះ មានការបណ្ដាក់ទុនលើគម្រោងវិនិយោគតាមមុខសញ្ញាផលិតកម្មថ្មីក្រៅពីវិស័យកាត់ដេរ មានជាអាទិ៍ ការដំឡើងរថយន្ត ម៉ូតូ កង់ ការផលិតម៉ូទ័រខ្នាតតូច ឧបករណ៍អគ្គិសនី ក្ដារបន្ទះ សក់សិប្បនិម្មិត ជ្យូងអនាម័យ និងការផលិតសម្ភារៈក្មេងលេង។

## ២-ឧស្សាហកម្ម និងសិប្បកម្ម

- គិតត្រឹមដំណាច់ឆ្នាំ២០១២នេះ រោងចក្រដែលបានចុះបញ្ជីនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានចំនួនសរុប៩០៧ កើនឡើង ២៦៤រោងចក្រ ស្មើនឹង ៤១,០៥% បើធៀបនឹងឆ្នាំ ២០០៨ និងប្រើប្រាស់ពលករសរុប ៥៥៩ ៥៨៥នាក់ កើនឡើង ៨៩ ៣០០នាក់ ស្មើនឹង ១៨,៩៨% បើធៀបនឹងឆ្នាំ២០០៨ ក្នុងនោះ រោងចក្រកាត់ដេរនិងចាក់ មាន ៥៤៣ កើនឡើង ៤២ រោងចក្រ ស្មើនឹង ៨,៣៨% បើធៀបនឹងឆ្នាំ ២០០៨ និងមានពលករបម្រើការងារ ៤៩២ ៥២០នាក់ កើនឡើង ៦៦ ៦៥២នាក់ ស្មើនឹង ១៥,៦៥% បើធៀបនឹងឆ្នាំ២០០៨។
- នៅឆ្នាំ២០១២នេះ មូលដ្ឋានឧស្សាហកម្មតូចសិប្បកម្មមានចំនួន ៣៨ ០៥០មូលដ្ឋាន កើនឡើង ៥ ២៥០ មូលដ្ឋាន ស្មើនឹង ១៦% បើធៀបនឹងឆ្នាំ២០០៨ ។ ចំនួនពលករសរុបមកដល់ឆ្នាំ២០១២នេះមាន ១៨៥ ៦២៧នាក់ កើនឡើង ៨៨ ៧៤៤នាក់ ស្មើនឹង ៩១,៥៩% បើធៀបនឹងឆ្នាំ២០០៨។
- យោងតាមការធ្វើជំរឿនសេដ្ឋកិច្ចក្នុងឆ្នាំ២០១១ មាន ៥០៣ ០០៨មូលដ្ឋាន បាននិងកំពុងធ្វើសកម្មភាពអាជីវកម្ម និងផលិតកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាអាទិ៍ នៅរាជធានីភ្នំពេញមាន ៩៥ ៤៦៧មូលដ្ឋាន ស្មើនឹង ១៩% ខេត្តកំពង់ចាមមាន ៥៥ ៩០៣មូលដ្ឋាន ស្មើនឹង ១១,១% ខេត្តកណ្ដាល មាន ៤០ ៣៥៩ មូលដ្ឋានស្មើនឹង ៨% ខេត្តបាត់ដំបង មាន ៣៣ ៩៨២ មូលដ្ឋាន ស្មើនឹង ៦,៨% និងខេត្តសៀមរាប មាន ៣២ ០២៤ មូលដ្ឋាន ស្មើនឹង ៦,៤%។

♦រាជរដ្ឋាភិបាលតាមរយៈក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (១)-កំពុងធ្វើការពង្រឹងយន្តការការពារកម្មសិទ្ធិឧស្សាហកម្ម ដើម្បីជំរុញលើកទឹកចិត្តដល់ការបង្កើតឡើងថ្មី (២)- កំពុងធ្វើការជំរុញលើកទឹកចិត្តដល់ការប្រើបច្ចេកទេសនិងបច្ចេកវិទ្យាថ្មីៗ (៣)-កំពុងធ្វើការបណ្តុះបណ្តាលជំនាញ និង(៤)-កំពុងធ្វើការពង្រឹងក្របខណ្ឌច្បាប់។

♦គោលនយោបាយ "ភូមិមួយ ផលិតផលមួយ" កំពុងត្រូវបានបន្តអនុវត្តក្នុងរូបភាពគំរូសាកល្បងនៅតំបន់ជនបទមួយចំនួន។

## ៣- ការបង្កើតការងារ និងការធានាលក្ខខណ្ឌការងារល្អប្រសើរ

♦ចាប់ពីឆ្នាំ២០០៩ដល់ឆ្នាំ២០១២ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរកការងារឲ្យប្រជាពលរដ្ឋធ្វើចំនួន ២០៥ ៦២៤នាក់ ដែលជាប្រជាពលរដ្ឋរស់នៅរាជធានីភ្នំពេញ ក្នុងនោះ ធ្វើការនៅក្នុងប្រទេស ចំនួន ១០៧ ០៦៨នាក់ និងទៅធ្វើការនៅក្រៅប្រទេសចំនួន ៩៨ ៥៥៦នាក់ តាមរយៈក្រុមហ៊ុនចំនួន៣១ និងតាមប្រព័ន្ធអនុញ្ញាតមុខរបរ EPS នៅតាមបណ្តាប្រទេសដូចខាងក្រោម៖

១- ប្រទេសថៃៈ តាមរយៈក្រុមហ៊ុនចំនួន២៣ មានពលករសរុបចំនួន ៥១ ៦០១នាក់ (ស្រី ២០ ៤៥៤នាក់)។

២- ប្រទេសម៉ាឡេស៊ីៈ តាមរយៈ២០ក្រុមហ៊ុន មានពលករសរុបចំនួន ៣០ ៥៨៩នាក់ (ស្រី ២៦ ៦៣៥នាក់)។

៣- សាធារណរដ្ឋកូរ៉េៈ តាមរយៈគណៈកម្មាធិការបណ្តុះណ្តាល និបញ្ជូនពលករទៅបរទេសតាមប្រព័ន្ធអនុញ្ញាតមុខរបរ(EPS)ចំនួន ១៦ ១៧៧នាក់(ស្រី ២ ៣៨៨នាក់)។

៤- ប្រទេសជប៉ុនៈ តាមរយៈក្រុមហ៊ុនចំនួន០៤ មានពលករសរុបចំនួន ១៨៩នាក់(ស្រី ២៤នាក់)។

### ✡ការបង្កើតការងារនិងចំណូលពីវិស័យទេសចរណ៍

| បរិយាយ | ឯកតា | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ |
|---|---|---|---|---|---|---|
| ទេសចរអន្តរជាតិ | លាននាក់ | ២,១៣ | ២,១៦ | ២,៥១ | ២,៨៨ | ៣,៥៨ |
| ទេសចរជាតិ | លាននាក់ | ៦,៧៣ | ៧,០២ | ៧,៥៦ | ៧,៨១ | ៨,២៥ |
| កម្លាំងពលកម្ម | ពាន់នាក់ | ៣០០ | ៣០៥ | ៣១៥ | ៣៥០ | ៣៧៥ |
| ចំណូលពីវិស័យទេសចរណ៍ | លានដុល្លារអាមេរិក | ១ ៥៩៥ | ១ ៥៦១ | ១ ៧៨៦ | ១ ៩១២ | ២ ២១០ |
| ការស្នាក់នៅ | បន្ទប់ | ៣២ ៨៥៨ | ៣៧ ៥២២ | ៣៩ ៧១៤ | ៤៣ ២៣៦ | ៤៦ ៤៤៦ |

## ✡ចំនួនភ្ញៀវទេសចរអន្តរជាតិនិងចំណូលពីការទិញសំបុត្រ ចូលទស្សនារមណីយដ្ឋានអង្គរ

| ឆ្នាំ | ចំនួនភ្ញៀវទេសចរអន្តរជាតិ(នាក់) | ចំណូលពីការទិញសំបុត្រ (ដុល្លារអាមេរិក) |
|---|---|---|
| ២០០៨ | ១ ០៥៦ ៧៧៣ | ៣០ ៧៨៩ ១៦០ |
| ២០០៩ | ៩១៧ ៦៥០ | ២៦ ៦៥៩ ៤០០ |
| ២០១០ | ១ ១៥៥ ០៥៥ | ៣៣ ១១៣ ៥០០ |
| ២០១១ | ១ ៤៤២ ៦១១ | ៤២ ១៨៥ ៣០០ |
| ២០១២ | ១ ៨០៨ ៦២៣ | ៥១ ៣១៩ ១៨០ |
| សរុបរួម | ៦ ៣៨០ ៧១២ | ១៨៤ ០៦៦ ៥៤០ |

♦រមណីយដ្ឋានទេសចរណ៍កំពុងពេញនិយមទទួលភ្ញៀវទេសចរជាតិ និងអន្តរជាតិសរុប៖

-រមណីយដ្ឋានប្រាសាទបុរាណ (ក្រៅពីតំបន់អង្គរ) ៣៣៥ កន្លែង

-ប្រាសាទបុរាណបែកបាក់ខ្លះៗ ៥៨២កន្លែង

-វត្ថុបុរាណ ១ ១០៤ កន្លែង

-ស្ពានបុរាណ ១០៧ កន្លែង

-រមណីយដ្ឋានទេសចរណ៍ធម្មជាតិ ១៥៩ កន្លែង

-រមណីយដ្ឋានទេសចរណ៍កែច្នៃ ៦០ កន្លែង

-រមណីយដ្ឋានមានអាជ្ញាបណ្ណទេសចរណ៍(ឯកជន) ១៦ កន្លែង

-រមណីយដ្ឋានទេសចរណ៍ទទួលបានចំណាត់ថ្នាក់ ០៨ កន្លែង

♦ប្រាសាទព្រះវិហារ ត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក កាលពីថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៨។

♦ គិតចាប់ពីឆ្នាំ ២០០៨ ដល់ ឆ្នាំ២០១២ នៅព្រះរាជាណាចក្រកម្ពុជា មានសណ្ឋាគារផ្កាយ១ ចំនួន០៥ សណ្ឋាគារផ្កាយ២ ចំនួន០៦ សណ្ឋាគារផ្កាយ៣ ចំនួន ៣០ សណ្ឋាគារផ្កាយ៤ ចំនួន ៥១ និងសណ្ឋាគារផ្កាយ៥ ចំនួន២៣។

- រាជរដ្ឋាភិបាលកម្ពុជាបានព្រមព្រៀងលើកលែងទិដ្ឋាការចំពោះភ្ញៀវទេសចរអន្តរជាតិនៃប្រទេស សិង្ហបុរី ម៉ាឡេស៊ី ហ្វីលីពីន ឡាវ វៀតណាម ថៃ និងប្រទេសឥណ្ឌូនេស៊ី។ ចំណែកប្រទេសប្រ៊ុយណេ និងប្រទេសមីយ៉ាន់ម៉ា នៅពុំទាន់បានលើកលែងទិដ្ឋាការនៅឡើយទេ។
- ប៉ូលអភិវឌ្ឍន៍វិស័យទេសចរណ៍សំខាន់ៗ មាន រាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ តំបន់ឆ្នេរសមុទ្រ និងភូមិភាគឥសាន្តនៃព្រះរាជាណាចក្រកម្ពុជា។

## ៤- ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម

សហគ្រាសគ្រឹះស្ថានចំនួន ២ ៣០៥ បានចុះបញ្ជីជាមួយនឹងបេឡាជាតិសន្តិសុខសង្គម ហើយនៅក្នុងចំណោមសហគ្រាសគ្រឹះស្ថានទាំងនោះ សហគ្រាសគ្រឹះស្ថានចំនួន ២ ២៣៦ ត្រូវបានសុំឲ្យបង់វិភាគទានសម្រាប់បេឡាជាតិសន្តិសុខសង្គម។ នៅក្នុងចំណោមសហគ្រាសគ្រឹះស្ថានដែលមានកាតព្វកិច្ចបង់វិភាគទានសម្រាប់បេឡាជាតិសន្តិសុខសង្គមមាន ៨៦% បានបង់វិភាគទាន។

# IV-ការកសាងសមត្ថភាពនិងធនធានមនុស្ស

## ១-ការពង្រឹងគុណភាពវិស័យអប់រំ

| | | | | |
|---|---|---|---|---|
| **មត្តេយ្យសិក្សា** | | | | |
| ឆ្នាំសិក្សា | ២០០៩-២០១០ | ២០១០-២០១១ | ២០១១-២០១២ | ២០១២-២០១៣ |
| សាលា | ១ ៨៩៥ | ២ ០៩២ | ២ ៥៧៥ | ២ ៨១៣ |
| សិស្ស (នាក់) | ៩៩ ១៣០ (ស្រី ៤៩ ៥៧៤) | ១០៣ ៣១៥ (ស្រី ៥១ ៦៣៤) | ១២១ ៣០៦ (ស្រី ៦០ ៦៤៣) | ១២៨ ២៥៧ (ស្រី ៦៤ ០៦៥ ) |
| **បឋមសិក្សា** | | | | |
| ឆ្នាំសិក្សា | ២០០៩-២០១០ | ២០១០-២០១១ | ២០១១-២០១២ | ២០១២-២០១៣ |
| សាលា | ៦ ៦៦៥ | ៦ ៧៦៧ | ៦ ៨៤៩ | ៦ ៩១០ |
| សិស្ស (នាក់) | ២ ២៤០ ៦៣៣ (ស្រី ១ ០៧០ ០៨៣ ) | ២ ១៩១ ១៩២ (ស្រី ១ ០៤៣ ៣៨២) | ២ ១៤២ ៨៦៤ (ស្រី ១ ០២១ ៥៩១) | ២ ១៧៣ ៣៨៤ (ស្រី១ ០២២ ៩៨៣ ) |
| **មធ្យមសិក្សា**<br>**ក-មធ្យមសិក្សាបឋមភូមិ** | | | | |
| ឆ្នាំសិក្សា | ២០០៩-២០១០ | ២០១០-២០១១ | ២០១១-២០១២ | ២០១២-២០១៣ |
| អនុវិទ្យាល័យ | ១ ១៧២ | ១ ១៨៩ | ១ ១៩៦ | ១ ២១៤ |
| សិស្ស (នាក់) | ៥៨៥ ១១៥ (ស្រី ២៧៩ ៥២៧ ) | ៥៦០ ៨៦៨ (ស្រី ២៧០ ៤៥៨) | ៥៤១ ១៤៧ (ស្រី ២៦៣ ៥៩៣) | ៥៣៤ ៧១០ (ស្រី ២៦៣ ៣៦៩ ) |

| | | | | |
|---|---|---|---|---|
| លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ | | | | |
| បេក្ខជនមកប្រឡង (នាក់) | ១៤៣ ៩៥៤ (ស្រី ៦៦ ២១០) | ១៣០ ០០២ (ស្រី ៦០ ៤៤១) | ១១៦ ៦៩៥ (ស្រី ៥៥ ៥៤៧) | |
| បេក្ខជនប្រឡងជាប់ (នាក់) | ១៣២ ១៨៩ (ស្រី ៦២ ៤៣២) ស្មើនឹង ៩១,៨៣% | ១២១ ១០១ (ស្រី ៥៧ ៦៤៤) ស្មើនឹង ៩៣,១៥% | ១០៩ ០៤៩ (ស្រី ៥៣ ០៨២) ស្មើនឹង ៩៣,៤៥% | |

## ខ-មធ្យមសិក្សាទុតិយភូមិ

| ឆ្នាំសិក្សា | ២០០៩-២០១០ | ២០១០-២០១១ | ២០១១-២០១២ | ២០១២-២០១៣ |
|---|---|---|---|---|
| វិទ្យាល័យ | ៣៨៣ | ៤០៧ | ៤២៦ | ៤៣៣ |
| សិស្ស (នាក់) | ៣២៣ ៥៨៣ (ស្រី ១៤០ ៩៣៧) | ៣៣៤ ៧៣៤ (ស្រី ១៥០ ៤៧២) | ៣១៨ ១៦៥ (ស្រី ១៤៥ ៥១៧ ) | ២៨៨ ៧៨៩ (ស្រី ១៣៤ ៦០៨) |
| លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ | | | | |
| បេក្ខជនមក | ១០៦ ៩០៨ | ១១១ ២៨៧ | ១១១ ០៤០ | |
| ប្រឡង (នាក់) | (ស្រី ៤៣ ០៤០) | | (ស្រី ៤៨ ៨៤០) | |
| បេក្ខជនប្រឡងជាប់ (នាក់) | ៨៧ ៥៦១ (ស្រី ៣៧ ៧៣៧) ស្មើនឹង ៨១,៩០% | ៩២ ២៣៦ (ស្រី ៤១ ៦៣៣) ស្មើនឹង ៨២,៨៨% | ៩៦ ០២៣ (ស្រី ៤៤ ៧១១) ស្មើនឹង ៨៦,៤៨% | |

## ឧត្តមសិក្សា

| ឆ្នាំសិក្សា | ២០០៩-២០១០ | ២០១០-២០១១ | ២០១១-២០១២ | ២០១២-២០១៣ |
|---|---|---|---|---|
| គ្រឹះស្ថានរដ្ឋ (១) | ៣២ | ៣៥ | ៣៨ | ៣៩ |
| គ្រឹះស្ថានឯកជន(២) | ៤៤ | ៥៥ | ៥៩ | ៦២ |
| សរុប ១+២ | ៧៦ | ៩០ | ៩៧ | ១០១ |
| និស្សិតថ្នាក់បរិញ្ញាបត្ររង(នាក់) | ២០ ៧១៩ | ២៣ ១២៣ (ស្រី ៧ ៨៦១ ) | ២២ ០២៤ (ស្រី ៧ ៣៥៥) | ២៣ ៦៧៨ (ស្រី ៧ ៩៤៤) |
| និស្សិតថ្នាក់បរិញ្ញាបត្រ(នាក់) | ១៧៣ ២៦៤ (ស្រី ៧០ ៩៥៤) | ២០៧ ៦៦៦ (ស្រី ៨៣ ៤៦៣) | ១៨៥ ៩១៨ (ស្រី ៧៣ ៨២៥) | ២១៦ ០៥៣ (ស្រី ៨៦ ២៣៥) |
| និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់(នាក់) | ១២ ៨០៣ (ស្រី ២ ២៥៨) | ១២ ២៨៦ (ស្រី ២ ១៨៣ ) | ៣ ៦៥០ (ស្រី ៧៧៣) | ៦ ១៦០ (ស្រី ១២៩) |
| បណ្ឌិត(នាក់) | ៩៥៦ (ស្រី៥៣) | ៩៦៨ (ស្រី៥៣) | ៤៥ (ស្រី០២) | ១៤២ (ស្រី៥៤) |

## ✡ ការបណ្តុះបណ្តាលនៅសាលាភូមិន្ទរដ្ឋបាល

| ឆ្នាំសិក្សា | ផ្នែកបណ្តុះបណ្តាលដំបូង | ផ្នែកបណ្តុះបណ្តាលបន្ត |
|---|---|---|
| ២០០៨-២០០៩ | សិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី៥ចំនួន ៥០នាក់ (ស្រី ០៩នាក់)<br>សិស្សមន្ត្រីក្រមការជំនាន់ទី៣ ចំនួន ៥០នាក់ (ស្រី១០នាក់) | កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ ១០៩នាក់ (ស្រី ១៤នាក់)<br>កម្មសិក្សាការីមន្ត្រីមធ្យមចំនួន ១០៧នាក់ (ស្រី ១៧នាក់) |
| ២០០៩-២០១០ | សិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី៦ចំនួន ៥០នាក់ (ស្រី ១២នាក់) | កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ ១១៥នាក់ (ស្រី ៨នាក់)<br>កម្មសិក្សាការីមន្ត្រីមធ្យម១១០នាក់ (ស្រី២៦នាក់)<br>មន្ត្រីមកពីស្ថាប័នព្រឹទ្ធសភា ៨៥នាក់ (ស្រី ១០នាក់) |
| ២០១០-២០១១ | សិស្សមន្ត្រីក្រមការជំនាន់ទី៤ ចំនួន ៩៦នាក់ (ស្រី២១នាក់) | កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ ១០៨នាក់ (ស្រី ៨នាក់)<br>កម្មសិក្សាការីមន្ត្រីមធ្យម ៧៥នាក់ (ស្រី ៩នាក់) |
| ២០១១-២០១២ | សិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី៧ចំនួន ៦០នាក់ (ស្រី ១៣នាក់)<br>សិស្សមន្ត្រីក្រមការជំនាន់ទី៥ ចំនួន ៧១នាក់ (ស្រី២៩នាក់) | កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ ៩៣នាក់ (ស្រី ៩នាក់)<br>កម្មសិក្សាការីមន្ត្រីមធ្យម ៧៨នាក់ (ស្រី ១៨នាក់) |

## ២-ការលើកកម្ពស់វិស័យសុខាភិបាល

### ក-មូលដ្ឋានសុខាភិបាលសាធារណៈ

| ឆ្នាំ | មន្ទីរពេទ្យជាតិ | មន្ទីរពេទ្យបង្អែក | មណ្ឌលសុខភាព | ប៉ុស្តិ៍សុខភាព | ស្រុកប្រតិបត្តិ |
|---|---|---|---|---|---|
| ២០០៨ | ០៨ | ៧៩ | ៩៦៧ | ១០៧ | ៧៧ |
| ២០០៩ | ០៨ | ៨០ | ៩៨៤ | ១១១ | ៧៧ |
| ២០១០ | ០៨ | ៨១ | ៩៩៧ | ១១៧ | ៧៧ |
| ២០១១ | ០៨ | ៨២ | ១០០៤ | ១២៣ | ៧៧ |
| ២០១២ | ០៨ | ៨៣ | ១០២៤ | ១២១ | ៧៩ |

- មន្ទីរពេទ្យជាតិ ចំនួន០៨ ក្នុងនោះ មានមជ្ឈមណ្ឌលជាតិ ចំនួន០២ ដែលមានសកម្មភាពការងារជាមន្ទីរពេទ្យ គឺមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក និងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺរបេង និងហង់សិន។
- មន្ទីរពេទ្យសរុបទាំង៩១ ក្នុងនោះមានមន្ទីរពេទ្យជាតិ០៨ មន្ទីរពេទ្យរាជធានី ខេត្ត២៤ និងមន្ទីរពេទ្យ បង្អែកនៅថ្នាក់ស្រុក៥៩។ មន្ទីរពេទ្យទាំងអស់នេះ មានចំនួនគ្រែសរុប ១២ ៦៥១គ្រែ ក្នុងនោះមានគ្រែសម្រាប់អ្នកជំងឺរបេង ២ ៧៤១គ្រែ។ ចំនួនគ្រែនៅមន្ទីរពេទ្យសាធារណៈនៅឆ្នាំ២០០៨ មានចំនួន ៨ ៩៨៦គ្រែ និងនៅឆ្នាំ២០១២បានកើនឡើងដល់ ១២ ៦៥១គ្រែ ស្មើនឹង ៤០,៧៨%។

### ខ-ចំនួនមន្ត្រីសុខាភិបាល(ឯកតា: នាក់)

| បរិយាយ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ |
|---|---|---|---|---|---|
| វេជ្ជបណ្ឌិត (១) | ២ ១៧៣ | ២ ១៦២ | ២ ១៣៩ | ២ ១៨០ | ២ ១៧៨ |
| គ្រូពេទ្យមធ្យម | ១ ២២០ | ១ ១៤៧ | ១ ០៨៧ | ១ ០៥២ | ១ ០១៨ |
| ទន្តបណ្ឌិត | ១៧២ | ១៧៧ | ១៨៩ | ២១២ | ២១៤ |
| ឱសថការី | ៤២៧ | ៤៣៥ | ៤៦៤ | ៤៧៤ | ៤៨៦ |
| ឆ្មបមធ្យម | ១ ៨០៦ | ១ ៨២៥ | ១ ៨៦៣ | ១ ៩៩៤ | ២ ៤៣២ |
| គិលានុបដ្ឋាក/ គិលានុបដ្ឋាយិកាមធ្យម | ៥ ០៨៤ | ៥ ០៩៨ | ៥ ១៥៥ | ៥ ៣៦៦ | ៥ ៦៦២ |
| ឆ្មបបឋម | ១ ៤៣៩ | ១ ៦១៦ | ១ ៨១៥ | ១ ៩៩៧ | ២ ១៦៤ |
| គិលានុបដ្ឋាក/ គិលានុបដ្ឋាយិកាបឋម | ៣ ៤០៧ | ៣ ៤០៤ | ៣ ៣៥៩ | ៣ ៣៨១ | ៣ ៣៦៦ |
| អ្នកបច្ចេកទេសមធ្យម | ៤២៨ | ៤២០ | ៤២៤ | ៤៤២ | ៤៥៤ |
| បុគ្គលិកផ្សេងៗ(២) | ១ ៩៤០ | ១ ៨២៩ | ១ ៨០៧ | ១ ៧១៦ | ១ ៧៤៧ |

(១) រួមមាន៖ វេជ្ជបណ្ឌិត វេជ្ជបណ្ឌិតឯកទេស និងសាស្ត្រាចារ្យ

(២) រួមមាន៖ ឱសថការីបណ្ឌិត ឱសថការីមធ្យម ឱសថការីបឋម ទន្តពេទ្យ ទន្តគិលានុបដ្ឋាក ពេទ្យធ្មេញបឋម បរិញ្ញាបត្រគិលានុបដ្ឋាក បរិញ្ញាបត្រឆ្មប ព្យាបាលដោយចលនា មន្ទីរពិសោធន៍បឋម វិទ្យុសាស្ត្រ ជំនាញក្រៅសុខាភិបាល និងផ្សេងៗ។

### គ-ឱសថស្ថាន ឱសថស្ថានរង និងផ្ទះលក់ឱសថ

- គិតត្រឹមដំណាច់ឆ្នាំ២០១២ ឱសថស្ថាន និងឱសថស្ថានរង នៅទូទាំងប្រទេស មានចំនួនសរុប ១ ៦៩៩កន្លែង។ ផ្ទះលក់ឱសថអត់ច្បាប់ទាំងអស់ ត្រូវបានលុបបំបាត់ចោលទាំងស្រុងនៅចុង

ឆ្នាំ២០១១ ហើយបានធ្វើឲ្យការលក់ឱសថក្លែងក្លាយ ឱសថអន់គុណភាព និងឱសថគ្មានប្រភពច្បាស់លាស់ ត្រូវបានកាត់បន្ថយដល់កម្រិតទាបបំផុត(០,៥០%)នៅឆ្នាំ២០១០ មកត្រឹម០,១៨% នៅឆ្នាំ២០១១ និងមកត្រឹម០,១៣% នៅឆ្នាំ ២០១២។

| ស្ថិតិឱសថស្ថាន ឱសថស្ថានរង និងផ្ទះលក់ឱសថ | | | | | |
|---|---|---|---|---|---|
| ចំនួនទីតាំង | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ |
| សរុប | ២ ៦១០ | ២ ៣៦១ | ១ ៦០៨ | ១ ៥២១ | ១ ៦៩៩ |
| ឱសថស្ថាន/ឱសថស្ថានរង មានច្បាប់ | ១ ៣៧១ (៥២,៥ %) | ១ ៤៥៣ (៦១,៥%) | ១ ៥២១ (៩៤,៦%) | ១ ៥២១ (១០០%) | ១ ៦៩៩ (១០០%) |
| ផ្ទះលក់ឱសថ អត់ច្បាប់ | ១ ២៣៩ (៤៧,៥%) | ៩០៨ (៣៨,៥%) | ៨៧ (៥,៤%) | ០ (០%) | ០ (០%) |

## ឃ-សេវាសុខាភិបាលឯកជន

| ស្ថិតិសេវាសុខាភិបាលឯកជន | | | | | |
|---|---|---|---|---|---|
| បរិយាយ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ |
| ចំនួនសេវាសរុប (កន្លែង) | ៣ ៦៩០ | ៣ ៧៥៥ | ៤ ៦២២ | ៤ ៩៧០ | ៥ ៥០១ |
| មានច្បាប់ | ១ ៥១៣ (៤១%) | ២ ៧០០ (៧២%) | ៤ ៣១៧ (៩៣%) | ៤ ៩៧០ (១០០%) | ៥ ៥០១ (១០០%) |
| អត់ច្បាប់ | ២ ១៧៧ (៥៩%) | ១ ០៥៥ (២៨%) | ៣០៥ (៧%) | ០ (០%) | ០ (០%) |

# ៣-កិច្ចការសាសនា

## ក-ព្រះពុទ្ធសាសនា

| បរិយាយ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ |
|---|---|---|---|---|---|
| ចំនួនវត្ត | ៤ ៣៣១ | ៤ ៣៩២ | ៤ ៤៦៦ | ៤ ៥១៤ | ៤ ៥៥៣ |
| ចំនួនព្រះសង្ឃ (អង្គ) | ៥៦ ០៤០ | ៥៤ ៧៦៤ | ៥៦ ៣០៤ | ៥៦ ៨២០ | ៥៣ ២៥៧ |

## ខ-អិស្លាមសាសនា

| បរិយាយ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ |
|---|---|---|---|---|---|
| វិហារ (កន្លែង) | ២៥៤ | ២៨០ | ៣៣៥ | ៣៩២ | ៤៣៩ |
| បរិស័ទ (នាក់) | ៤៦៣ ៧៣២ | ៤៦៣ ៨១៩ | ៤៨២ ៨៦៣ | ៣២០ ៤១៩ | ៣៤២ ៩៩០ |

## គ-គ្រិស្តសាសនា

| បរិយាយ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ |
|---|---|---|---|---|---|
| កាតូលិក | | | | | |
| វិហារ (កន្លែង) | ២៥ | ២៩ | ៤៣ | ៤០ | ៥៥ |
| បរិស័ទ (នាក់) | ៨ ៧៥៥ | ៩ ៤២៩ | ៩ ១១១ | ៨ ៦២៣ | ១២ ៩៧៣ |
| ប្រូតេស្តង់ | | | | | |
| វិហារ (កន្លែង) | ២៣៧ | ៣៤១ | ៤៧៩ | ៤៦៥ | ៤៣០ |
| បរិស័ទ (នាក់) | ១០៣ ៦៤៣ | ៦៩ ៨៦៦ | ៧១ ០៣០ | ៨៥ ០៦៥ | ៨៣ ០៨៦ |

ក្រៅពីនេះមាន សាសនាមហាយាន សាសនាបាហៃ និងសាសនាកៅដាយ។ល។

## ៤- ការលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី

ស្ថានភាពរបស់ស្ត្រីទទួលបាននូវវឌ្ឍនភាពជាច្រើន។ នៅព្រះរាជាណាចក្រកម្ពុជា មានស្ត្រីជាអនុប្រធានរដ្ឋសភា និងជាឧបនាយករដ្ឋមន្ត្រី។ លើសពីនេះ ស្ថាប័នរាជរដ្ឋាភិបាលចំនួន៤ កំពុងត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីជាស្ត្រី ហើយស្ត្រីជារដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ បានកើនឡើងពី ២៧រូប ក្នុងឆ្នាំ២០០៨ ដល់ ៥៤រូបក្នុងឆ្នាំ២០១២។ ស្ត្រីចំនួន ១៩៧រូប បានក្លាយជាអភិបាលរងនៅគ្រប់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌទូទាំងប្រទេស។ សមាមាត្រនៃចំនួនស្ត្រីជាមន្ត្រីរាជការបានកើនដល់ ៣៤%។ ជំរឿនសេដ្ឋកិច្ចឆ្នាំ២០១១ បានបង្ហាញថា ក្នុងចំណោមអ្នកធ្វើការក្នុងសហគ្រាសសរុបចំនួន ១,៦លាននាក់ មានស្ត្រី ១លាននាក់ គឺស្មើនឹង ៦១%។

## ✡✡✡សមិទ្ធផលសំខាន់ៗដែលត្រូវបានសម្ពោធដាក់ឲ្យប្រើប្រាស់ ចាប់ពីឆ្នាំ២០០៩ដល់ឆ្នាំ២០១២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ក-ស្ពាន

១-ស្ពានស្ទឹងមានជ័យ ស្ថិតនៅចំណុចប្រសព្វរវាងខណ្ឌមានជ័យ ខណ្ឌចំការមន និងខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៦ ខែមករា ឆ្នាំ២០០៩។

២-ស្ពានកោះសំពៅមាស ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធនៅលើកោះមាស នៅក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី១០ ខែមករា ឆ្នាំ២០០៩។

៣-ស្ពានព្រះមុនីវង្សថ្មីនៅសង្កាត់ច្បារអំពៅ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០០៩។

៤-ស្ពានព្រែកក្ដាម ឆ្លងកាត់ទន្លេសាប ខេត្តកណ្ដាល មានបណ្ដោយ ៩៧៥ម ទទឹង ១៣,៥០ម កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០។

៥-ស្ពានអាកាស (ក្បាលថ្នល់) រាជធានីភ្នំពេញ ប្រវែង ៣០៨ម ទទឹង ១៤,២០ម កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១០។

៦-ស្ពានព្រែកព្នៅ ឆ្លងកាត់ទន្លេសាប រាជធានីភ្នំពេញ មានបណ្ដោយ ៩៦៦,២០ម ទទឹង ១៤ម កាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០។

៧-ស្ពានព្រែកតាមាក់ ឆ្លងកាត់ទន្លេមេគង្គ ខេត្តកណ្ដាល មានបណ្ដោយ ១០៦០ម ទទឹង ១៣,៥០ម កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១។

៨-ស្ពានតេជោមរកត (ស្ពានកោះពស់) ខេត្តព្រះសីហនុ មានបណ្ដោយ៩០០ម ទទឹង១២ម កាលពីថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១១។

៩-ស្ពានអាកាសប្រាំពីរមករា (ស្តុបពេទ្យលោកសង្ឃ) នៅចំទីតាំងប្រសព្វផ្លូវលេខ២៧១ ផ្លូវលេខ៥៩៨ និងវិថីកម្ពុជាក្រោម មានបណ្ដោយ៣៤៥ម ទទឹង១៥,២០ម (នៅចំពីលើចំណុចប្រសព្វ មានផ្លូវបែកជាចម្លាមមានបណ្ដោយប្រវែង ១៦០ម ទទឹង៦,៥០ម ជាផ្លូវឯកទិសចុះស្ពាន) រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០១២។

## ខ-ផ្លូវជាតិ និងផ្លូវលំជនបទ

១-គីរីវិថីសម្ដេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** នៅស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ កាលពីថ្ងៃទី៣១ខែ មីនា ឆ្នាំ២០០៩។

២-កំណាត់ផ្លូវជាតិលេខ៦៧ តភ្ជាប់ពីអន្លង់វែង មកសៀមរាប នៅស្រុកបន្ទាយស្រី ខេត្តសៀមរាប កាលពីថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ២០០៩។

៣-ផ្លូវជាតិលេខ៥ លេខ៦ សៀមរាប ប៉ោយប៉ែត និងស្ពាន លូ លើកំណាត់ផ្លូវជាតិលេខ ៥៦ លេខ៦៨ សិរីសោភ័ណ សំរោង ក្រឡាញ់ នៅស្រុកថ្មពួក ខេត្តសៀមរាប កាលពីថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០០៩។

៤-កំណាត់ផ្លូវជាតិលេខ១ ដំណាក់កាលទី២ ប្រវែង៤២,៨៨គ.ម. ពីកំពង់ចម្លងអ្នកលឿង ត្រើយខាងលិច មកដល់ផ្សារគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល នៅស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០១០។

៥-កំណាត់ផ្លូវជាតិលេខ៧៨ ប្រវែង៦៩,៥៦គ.ម. ពីបានលុង ខេត្តរតនគិរី ទៅអូរយ៉ាដាវ ព្រំប្រទល់កម្ពុជា-វៀតណាម កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០។

៦-កំណាត់ផ្លូវជាតិលេខ១ ដំណាក់កាលទី៣ ពីផ្សារគគីរ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ដល់វត្តក្ដីតាកុយ សង្កាត់វាលស្បូវ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ប្រវែង

៩,១០គ.ម. នៅសង្កាត់ព្រែកឯង ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១០។

៧-ផ្លូវជាតិលេខ៣ ពីរាជធានីភ្នំពេញ (ចោមចៅ)ដល់ក្រុងកំពត ខេត្តកំពត នៅសង្កាត់ចោមចៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ២០១១។

៨-កំណាត់ផ្លូវជាតិលេខ៦២ ពីត្បែងមានជ័យ ដល់ជើងភ្នំប្រាសាទព្រះវិហារ ប្រវែង ១១០,១០គ.ម. និងកំណាត់ផ្លូវលេខ២១០ ពីស្រយង់កោះកែ មកដល់ភូមិថ្នល់បត់ (បំបែកផ្លូវជាតិលេខ៦២) ប្រវែង៣៤,១៥គ.ម. នៅឃុំថ្មី ស្រុកគូលែន ខេត្តព្រះវិហារ កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១។

៩-កំណាត់ផ្លូវជាតិលេខ៧៦ ប្រវែង១២៧គ.ម. ពីស្នួល ខេត្តក្រចេះ ដល់ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី នៅក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២។

១០-ផ្លូវជាតិលេខ ៦៨ ប្រវែង ១១៧គ.ម ពីក្រឡាញ់ ខេត្តសៀមរាប ដល់អូរស្មាច់ ខេត្តឧត្តរមានជ័យ និងផ្លូវយុទ្ធសាស្ត្រព្រំដែន ឬបណ្តាញផ្លូវគមនាគមន៍ទិសឧត្តរ នៃមាតុភូមិកម្ពុជា ប្រវែង ១.២៨៧គ.ម. នៅឃុំកំពង់ថ្កូវ ស្រុកក្រឡាញ់ ខេត្តសៀមរាប កាលពីថ្ងៃទី ០៩ ខែមេសា ឆ្នាំ២០១២។

១១-សណ្ឋាគារ និងផ្លូវអ៊ុតកៅស៊ូបេទីម០៣ខ្សែ (ខ្សែទី១.មហារុក្ខវិថីគិរីតេជោ ខ្សែទី២. វិថីគិរីតេជោគង្គា និងខ្សែទី៣.វិថីតេជោសែនជ័យ) សរុបប្រវែង៤៩គ.ម. របស់ក្រុមហ៊ុនសុខាអូតែល នៅរមណីយដ្ឋានឋានសួគ៌បូកគោ ខេត្តកំពត កាលពីថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១២។

១២-កំណាត់ផ្លូវជាតិលេខ ៦២ ផ្នែកខាងត្បូង ពីខេត្តកំពង់ធំ ទៅក្រុងព្រះវិហារ ខេត្តព្រះវិហារ ប្រវែង១២៨គ.ម. នៅឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ កាលពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១២។

១៣-ផ្លូវជាតិលេខ៨ ពីស្ពានព្រែកតាមាក់ ខេត្តកណ្តាល ដល់អន្លង់ជ្រៃ ខេត្តកំពង់ចាម ព្រំប្រទល់កម្ពុជា-វៀតណាម ផ្លូវជាតិលេខ៨.១ ពីក្រពៅដល់មឺុនជ័យ ខេត្តព្រៃវែង ព្រំប្រទល់កម្ពុជា-វៀតណាម និងផ្លូវជាតិលេខ៨.២ ពីអន្លង់ជ្រៃដល់ពញាក្រែក ខេត្តកំពង់ចាម ប្រវែងសរុប១០៩គ.ម. នៅឃុំក្រពៅ ស្រុកកំចាយមារ ខេត្តព្រៃវែង កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១២។

១៤-ផ្លូវជាតិលេខ៧៨ ពីអូរពងមាន់ ខេត្តស្ទឹងត្រែង ដល់ក្រុងបានលុង ខេត្តរតនគិរី នៅខេត្តរតនគិរី កាលពីថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១២។

## គ-ស្ថានីយវារីអគ្គិសនី

១-ស្ថានីយវារីអគ្គិសនីកំចាយមានអានុភាព ១៩៣,២មេហ្គាវ៉ាត់ ចំណាយទឹកប្រាក់សរុបប្រមាណ២៨០លានដុល្លារអាមេរិក នៅឃុំ ម៉ាក់ប្រាង្គ ស្រុកទឹកឈូ ខេត្តកំពត កាលពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១១។

២-ស្ថានីយវារីអគ្គិសនីគិរីរម្យទី៣ មានអានុភាព១៨មេហ្គាវ៉ាត់ នៅឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង កាលពីថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០១៣។

## ឃ-ប្រព័ន្ធធារាសាស្ត្រ និងរោងចក្រផលិតទឹកស្អាត

១-ប្រព័ន្ធធារាសាស្ត្រចារឹក នៅឃុំស្យា ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី២១ខែមីនា ឆ្នាំ២០០៩។

២-រោងចក្រផលិតទឹកស្អាតជ្រោយចង្វា ជំហានទី២ នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩។

## ង-អគារសិក្សា

១-អគារសិក្សាសិក្សា១ខ្នង ២ជាន់ មាន១០បន្ទប់ នៅវិទ្យាល័យ **ហ៊ុន សែន ក្រាំងយ៉ូវ** នៅឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០០៩។

២-អគារសិក្សាសាកលវិទ្យាល័យបាត់ដំបង ស្ថិតនៅសង្កាត់ព្រះស្ដេច ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១០។

## ច-រោងចក្រ

១-រោងចក្រផលិតម៉ូទ័រខ្នាតតូច ក្រុមហ៊ុនមីនេបៀរ របស់ព្រះរាជាណាចក្រជប៉ុន ស្ថិតនៅតំបន់សេដ្ឋកិច្ចពិសេស សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១១។

២-រោងចក្រផលិតស្រាបៀរកម្ពុជា របស់ក្រុមហ៊ុនខ្មែរប្រ៊ូវើរី លីមីធីត នៅសង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១២។

៣-រោងចក្រផលិតជីកសិកម្មរបស់ក្រុមហ៊ុនជីអន្តរជាតិ ផ្កាយ៥កម្ពុជា នៅស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១២។

៤-រោងចក្រផលិតស្ករសរបស់ក្រុមហ៊ុនស៊ូហ្គើរ នៅឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃ២៧ ខែធ្នូ ឆ្នាំ២០១២។

## ឆ-តំបន់សេដ្ឋកិច្ចពិសេស

១-តំបន់សេដ្ឋកិច្ចពិសេសកំពង់ផែស្វយ័តក្រុងព្រះសីហនុ ដំណាក់កាលទី២ កាលពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១២។

២-តំបន់សេដ្ឋកិច្ចពិសេសកោះកុង នៅឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១២។

**ជ-ចំណតផែកុងតែន័រភ្នំពេញថ្មី**

ចំណតផែកុងតែន័រភ្នំពេញថ្មី នៅឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាលជាប់ផ្លូវជាតិលេខ១ ចម្ងាយ ៣០គ.ម. ពីរាជធានីភ្នំពេញ កាលពីថ្ងៃទី ២២ ខែមករា ឆ្នាំ២០១៣។

**ឈ-សមិទ្ធផលក្នុងវិស័យព្រះពុទ្ធសាសនា**

១-ពិធីកាត់ឫសសីមាព្រះវិហារ និងសម្ពោធសមិទ្ធផលនានានៅវត្តសន្សំកុសល នៅសង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី០៨ ខែ កុម្ភៈ ឆ្នាំ ២០០៩។

២-ពិធីកាត់ឫសសីមាព្រះវិហារ និងសម្ពោធសមិទ្ធផលនានានៅវត្តសត្ថារាម ហៅវត្តអង្គសង្កែ នៅឃុំ ត្រពាំងក្រញូង ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីព្រឹកថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៩។

៣-ពិធីកាត់ឫសសីមាព្រះវិហារ និងសម្ពោធសមិទ្ធផលនានា នៅវត្តវណ្ណរង្សី ហៅវត្តសំរោង នៅឃុំមនោរម្យ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ កាលពីព្រឹកថ្ងៃទី០៩ ខែមីនា ឆ្នាំ ២០០៩។

៤-ពិធីបុណ្យពុទ្ធាភិសេកព្រះពុទ្ធរូបអង្គធំ និងសម្ពោធសមិទ្ធផលនានា នៅវត្តភ្នំ និងភ្នំជីតាពេជ្រ ឃុំកំពែង ស្រុកគិរីវង់ ខេត្តតាកែវ កាលពីព្រឹកថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ ២០០៩។

៥-ពិធីកាត់ឫសសីមាព្រះវិហារ និងសម្ពោធសមិទ្ធផលនានានៅវត្តព្រៃអង្គរ ឃុំជូនតី ស្រុកពញាក្រែកខេត្តកំពង់ចាម កាលពីព្រឹកថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

៦-ពិធីសម្ពោធមហាកុដិ និងសមិទ្ធផលនានា នៅវត្តមុនីសុវណ្ណ ហៅវត្តចំពុះក្អែក នៅឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីព្រឹកថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១០។

៧-ពិធីសម្ពោធមហាកុដិ០១ខ្នង និងពិធីស្រោចស្រពព្រះសុគន្ធវារី ចម្រើនព្រះជន្មសម្ដេចព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត** ព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះចៅអធិការវត្តបទុមវតីគម្រប់៨៥ យាងចូល៨៦ព្រះវស្សា នៅវត្តបទុមវតី រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១០។

៨-ពិធីបញ្ចុះខណ្ឌសីមា ព្រះវិហារវត្តឯកសុវណ្ណ ហៅវត្តកូនក្អែក និងពិធីសម្ពោធអនុវិទ្យាល័យសម្ដេចតេជោ **ហ៊ុន សែន មង្គល**នៅឃុំរបស់មង្គល ស្រុកមោងឫស្សី ខេត្តបាត់ដំបង កាលពីព្រឹកថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១។

៩-ពិធីបញ្ចុះខណ្ឌសីមា ព្រះវិហារវត្តទួលសុវណ្ណារាម សម្ពោធសមិទ្ធផល និងពិធីចម្រើនព្រះជន្ម ព្រះមុនីកោសល **ហ៊ុល សុវណ្ណា** ព្រះអនុគណខណ្ឌឫស្សីកែវ និងជាព្រះចៅអធិការវត្តទួលសុវណ្ណារាមគម្រប់៨៧ យាងចូល៨៨ព្រះវស្សា នៅសង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១១។

រៀបចំចងក្រង និងបោះពុម្ពផ្សាយ

ដោយនាយកដ្ឋានសរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី

ទូរស័ព្ទលេខ : ០១២ ៨៨១ ៨៥៥ / ០៦៦ ៨៨១ ៨៥៥ / ០៩៧ ៦៦៦៦ ២៥៨

ទូរសារ : ០២៣ ២១២ ៤២៣

Email: lysivanna@gmail.com